**BMI0047**

## សម្ភាសន៍ជាមួយឈ្មោះ សំ យឿន ភេទប្រុស អាយុ៩១ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ អ្នកបោសសំអាតនៅក្រសួងការបរទេស

## មុខងារបច្ចុប្បន្នៈ កសិករ

## ស្រុកកំណើតនៅភូមិក្រាំងឈើនាង ឃុំត្បែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

## សព្វថ្ងៃរស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ឆាយ ឈុនលី

## ០១:២០:០៩

## ៣៧ទំព័រ

ឈុនលី ៖ ពូជួយប្រាប់ឈ្មោះ ពូឈ្មោះអី?

យឿន ៖ យឿន។

ឈុនលី ៖ ត្រកូលអីគេ?

យឿន ៖ សំ យឿន។

ឈុនលី ៖ អាយុប៉ុន្មានហើយ?

យឿន ៖ អាយុ៩១ឆ្នាំ។

ឈុនលី ៖ អានេះនៅភូមិអីគេ?

យឿន ៖ នេះនៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ។

ឈុនលី ៖ ពូស្រុកកំណើតនៅណា?

យឿន ៖ នៅខាងត្បូងភ្នំពេញ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

ឈុនលី ៖ ស្រុកកណ្ដាលស្ទឹង?

យឿន ៖ អឺ!

ឈុនលី ៖ ឃុំអីគេទៅ?

យឿន ៖ ឃុំត្បែង។

ឈុនលី ៖ ឃុំត្បែង ភូមិអីគេពូចាំអត់?

យឿន ៖ ភូមិក្រាំងឈើនាង។

ឈុនលី ៖ ភូមិក្រាំងឈើនាង ខ្ញុំចង់ដឹងថាមូលហេតុអីបានពូរត់មកដល់នេះ មកដល់ស្រុកម៉ាឡៃនេះ?

យឿន ៈ អានឹងកាលពីឆ្នាំ៧០ នឹងរដ្ឋប្រហារកាលនឹងខ្ញុំនៅវត្តទេ ។

ឈុនលី ៈ ឆ្នាំ៧០ ?

យឿន ៈ ហ្អឹងហើយ ទាល់តែពេលឆ្នាំ៧០ នឹងរដ្ឋប្រហារក៏លោកឲ្យមកនៅជាមួយឪពុកម្តាយវិញ ក៏ចឹងមកខាងភូមិ ។ អូ! និយាយពីប្រវត្តិនឹងកំសត់ណាស់ អ្នកភូមិយំសប្បើមណាស់ខ្ញុំ ក៏យំ ចុះវាមិនចង់បែកពីឪពុកម្តាយ ខាងគេខាងភូមិខាងឃុំគេបង្ខំណាស់ ។ ចុះបើយើងកាលនឹងយើងហ៊ានៗប្រឆាំង ហ៊ានប្រកែកមិនស្រួលបាត់ជីវិតទៀត ។ ហើយកាលនឹងខ្ញុំនៅកុមារទេ

ឈុនលី ៈ នៅកុមារអាយុប៉ុន្មានតូ?

យឿន ៈ ហ៎! អាយុអា១៨ ១៩ប៉ុននឹង ។

ឈុនលី ៈ ហើយម៉េចទៀតទៅ?

យឿន ៈ ដល់ពេលនេះគេជំរុញមក កាលនឹងកំពុងស្ងួតគេទៅហៅដល់ស្រែនោះ ហើយឪពុកម្តាយ តែម្តាយខ្ញុំអត់ស្គាល់ទេ ។

ឈុនលី ៈ អ្នកណាអ្នកហៅនឹង?

យឿន ៈ ខាងភូមិ ប្រធានភូមិគេ តែឥឡូវវាយូរហើយភ្លេចឈ្មោះ មានតែឈ្មោះ ចាន់ ។

ឈុនលី ៈ ការហៅនឹងប្រាប់ថាម៉េចទៅ?

យឿន ៈ គេថាឲ្យទៅបម្រើថាបម្រើកុមារនោះចូលក្នុងជួរកុមារ តែយើងមិនចង់បែកនោះកាលយើងវានៅតូច ។

ឈុនលី ៈ តែអានឹងចូលឆ្នាំ៧០ ?

យឿន ៈ ហេ! ៧០ ៧១ ។

ឈុនលី ៈ ចឹង៧០ នៅវត្ត?

យឿន ៈ ហ្អឹងហើយ ៧០ នៅវត្តដល់ពេលនេះបានលោកៗគាសង្ឃរាជនឹង ដល់ពេលមើលទៅវាយ៉ាប់យឺនពេកឲ្យមកនៅជាមួយឪពុកម្តាយនឹង ។ ក្នុងឆ្នាំ៧០ ៧១ គេទៅរើបអូស ៧២ បានចេញ គេទៅអូស២-៣ដងបាន ។

ឈុនលី ៈ ៧២នឹងចេញៗណា?

យឿន ៈ ៧២នឹងចេញពីឪពុកម្តាយនឹង មកនៅជួរអគ្គភាពកុមារនឹង ។

ឈុនលី ៈ ចុះកាល៧១នឹងធ្វើអីទៅ?

យឿន ៈ ៧១នឹងគេកំពុងនៅ ។

ឈុនលី ៈ នៅជាមួយឪពុកម្តាយ?

យឿន ៈ ហ្អឹងហើយ ស្ងួង ។

ឈុនលី ៖ ដកធម្មតា?

យឿន ៖ កំពុងស្ទូងដកធម្មតានឹង គេទៅទាញគេទៅអូសហៅមកៗអត់យកមក ហើយឪពុកនោះក៏យំ ម្ដាយខ្ញុំអត់ស្គាល់ ម្ដាយស្លាប់តាំងពីខ្ញុំ អឺ!តែបងខ្ញុំមិនស្គាល់ច្បាស់ផង ។

ឈុនលី ៖ ចុះពូពីតូចមករស់នៅជាមួយឪពុករហូត?

យឿន ៖ ហ្នឹងហើយ

ឈុនលី ៖ ឪពុកពូឈ្មោះអីគេ?

យឿន ៖ យឹម ។

ឈុនលី ៖ ហើយពេលនឹងម៉េចទៀតទៅ ពេលហៅចេញមកចឹង?

យឿន ៖ ចេញមកកាលនឹងដល់ទៅហៅមុនដំបូងនឹងអត់មកទេ ទាល់តែគេហៅទៅក្រោយឡើងទៀត គេហៅទៀត វិលងបាន៣-៤ថ្ងៃក៏ហៅទៀត ហៅយើងក៏មកៗភូមិវិញ គេហៅណែនាំចេះ ចុះយើងក៏អត់ព្រមមក នៅទីងរីងរូសចឹង ។

ឈុនលី ៖ គេហៅៗគេថាឲ្យទៅណា មកធ្វើអី?

យឿន ៖ ទៅមកចូលនឹងជួរអង្គភាពកុមារ ។

ឈុនលី ៖ ឲ្យចូលអង្គភាពកុមារដើម្បីអី?

យឿន ៖ ទេ! គេមិននិយាយ គេថាឲ្យចូលក្នុងជួរអង្គភាពកុមារ តែដល់មកនឹងមាននឹងគេមានអ្នក គ្រប់គ្រងតទៅទៀត ហើយភូមិគេខាងអូស គេមកហៅទាំងភូមិនៅនេះ ។

ឈុនលី ៖ ហើយម៉េចទៀតទៅ អង្គភាពកុមារគេនៅណា?

យឿន ៖ វានៅស្រុកនឹងភូមិនឹងដែរ តែគ្រាន់ថា ។

ឈុនលី ៖ នៅស្រុកកណ្ដាលស្ទឹង?

យឿន ៖ ហ្នឹងហើយភូមិជាមួយនឹង តែគ្រាន់ថាវាមិនបាននៅភូមិជាមួយឪពុកម្ដាយ ។

ឈុនលី ៖ ហើយដល់ពេលចូលមកធ្វើអីខ្លះទៅខាងកុមារនឹង?

យឿន ៖ មានធ្វើអី គ្រាន់ថាគេរៀនហាត់សិល្បៈហាត់អី អ្នកណាចេះក៏ចេះទៅ អ្នកណាមិនចេះក៏ហីទៅ ។

ឈុនលី ៖ សិល្បៈ រាំច្រៀង?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ពូប្រុសៗគេឲ្យហាត់ដែរ?

យឿន ៖ អឺ! ហាត់ទាំងអស់ឲ្យតែកុមារ ហាត់ដើម្បីបំពាក់បំប៉នខាងផ្នែកសិល្បៈនឹង ។

ឈុនលី ៖ ចុះនៅក្នុងអង្គភាពកុមារនឹងហូបចុកអីម៉េចទៅ?

យឿន ៖ អូ! រឿងហូបចុកពិបាកដែរនឹង ជួនកាលក៏មានបបរលាយព្រលិត លាយពោតចឹងទៅ ហើយសម័យនឹងដូចដឹងស្រាប់ហើយ ។

ឈុនលី ៖ ហើយគ្នាច្រើនទេ ពូនៅនឹង?

យឿន ៖ គេជួនកាល៦០នាក់ ៨០នាក់ មានឈានដល់១០០នាក់ ។

ឈុនលី ៖ កុមារនឹង?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ មានស្រី មានប្រុស?

យឿន ៖ មាន ។

ឈុនលី ៖ តែខាងណាច្រើនជាង ស្រីប្រុសណា?

យឿន ៖ ទេ!វាមិនខាងណាច្រើន ខាងណាវាដូចស្មើតែគ្នា វាចំរុះចឹង ទៅមានម៉ាកន្លែងទេ កន្លែងយើងនេះម៉ាកន្លែងទៅ មានកន្លែងគេនោះផ្សេងទៀត មានតាមភូមិ ។

ឈុនលី ៖ ហើយហាត់សិល្បៈចឹង អត់មានធ្វើការអីទៀតទេ?

យឿន ៖ គេមាន ពេលណាប្រជាជនស្ទូងដកអីចឹង ជួនកាលហៅប្រមូលកុមារជួយយួរជួយសែងកណ្តាប់សែងអី កុមារប្រលែងគ្នាដួលប្រាសច្រូងទៅ តែធ្វើម៉េចឲ្យតែបានទៅប្រឡូកជាមួយសហករណ៍ទៅ ។

ឈុនលី ៖ កាលនឹងមានសហករណ៍ហើយឆ្នាំ៧១ ៧២?

យឿន ៖ នៅទេៗ ។

ឈុនលី ៖ ចុះពូថានៅអង្គភាពកុមារនឹងឆ្នាំណា?

យឿន ៖ ឆ្នាំ៧២ ៧៣នឹង ។

ឈុនលី ៖ ចុះពូនៅអង្គភាពនឹងប៉ុន្មានឆ្នាំ?

យឿន ៖ នៅបានប្រហែលជាម៉ាឆ្នាំ មិនដល់ម៉ាឆ្នាំផង តែ ។

ឈុនលី ៖ ចឹងវាឡើងដល់៧៣ មែនអត់?

យឿន ៖ ៧៣វាចេញពីកន្លែងនឹងមករបៀបថាចូលកុមារយោធា ។

ឈុនលី ៖ គេហៅថាកុមារយោធា?

យឿន ៖ ហ្នឹងហើយ កុមារយោធានឹងវារបៀបថាជញ្ជូនគ្រាប់បែក ដូចថាវៃបន្ទាយណាមួយបែកចឹងទៅ គេប្រមូលកុមារនឹងទៅយកគ្រាប់ ជញ្ជូនគ្រាន់ស្ពាយគ្រាប់នឹងយកមកទុកខាងក្រោយឃ្លាំង ។

ឈុនលី ៖ ជញ្ជូនគ្រាប់បែកអីទៅច្បាំងអីនឹង?

យឿន ៈ ហ្នឹងហើយ ជញ្ជូន ។

ឈុនលី ៈ ច្បាំងជាមួយខាងណាខ្លះទៅ?

យឿន ៈ ទេ! ច្បាំងជាមួយខ្មែរគ្នាឯងនឹង ។

ឈុនលី ៈ កាលនឹងជាមួយពួកលន់ នល់អីនឹង?

យឿន ៈ ហ្នឹងហើយ នេះមិនខ្មែរៗគ្នាឯងដែរនឹង តែយើងហ៊ាន គេ ។

ឈុនលី ៈ ចង់សួរថាធ្វើការដូចសែងគ្រាប់សែងអីចឹង កាលនឹងភ័យខ្លាច នៅតូច ក្មេង?

យឿន ៈ ទេ! នៅក្មេងតែគេបញ្ចូល តែមុនដំបូងនឹកផ្ទះ នឹកឪពុក យំ ហើយដល់មកគ្នាច្រើនទៅ គេបំពាក់បំប៉នចឹងទៅ ក៏សប្បាយនឹងគេនឹងឯងទៅ ។ អាពេលទៅជញ្ជូនកណ្តាប់ជញ្ជូនអី ក៏ប្រលែងគ្នាលេងពេញតែទឹកពេញភក់នឹង បាត់អារម្មណ៍លែងសូវនឹក ។ ដល់ពេលហូបចុកៗបាននឹកឃើញហើយ ឃើញចុះបបរជាមួយព្រលិត ជាមួយពោត ។

ឈុនលី ៈ ហូបអត់គ្រប់ទៀត?

យឿន ៈ អឺ! គ្រប់ឲ្យគ្រប់ម៉េចកើត ។

ឈុនលី ៈ ហើយបន្ទាប់ពីនឹងទៀត ធ្វើអីទៀតពូ?

យឿន ៈ បន្ទាប់ពីនឹងមក យើងចេះតែវាយើងជញ្ជូនគ្រាប់ជញ្ជូនអី ចេះយូរៗទៅយើងមានស្គាល់ ។

ឈុនលី ៈ ជញ្ជូនៗពីណា មកដាក់ណា?

យឿន ៈ ឧបមាថាគេវ៉ៃបែកបន្ទាយនឹងមួយ បែកបន្ទាយនឹង គេប្រមូល គេជញ្ជូនដាក់ខាងក្រៅនេះ គេអូសកុមារនឹងទៅស្ពាយពីនឹងយកមកដាក់ក្រោយនេះទៀត ដាក់សមរភូមិក្រោយនេះ ។

ឈុនលី ៈ វ៉ៃពីមុខហើយ យកមកដាក់ក្រោយអត់យកទៅមុខទៀត?

យឿន ៈ ហ៊ឺ! យកទៅមុខម៉េចកើត តែវ៉ៃហើយ គេបញ្ជូនមកក្រោយវិញហើយ ហើយទ័ពគេនឹង

ឈុនលី ៈ ប្រចាំការណ៍នៅនឹង?

យឿន ៈ ហ្នឹងហើយ គេប្រចាំក៏គេត្រៀមនឹងបណ្តោយ ។

ឈុនលី ៈ ចឹងគេវ៉ៃបានត្រង់ណា គេត្រៀមដល់កន្លែង?

យឿន ៈ បាទ! ហើយគ្រាប់ គេជញ្ជូនពីឃ្លាំងយកមកដាក់ខាងក្រៅបន្ទាយនឹង ឲ្យកុមារនឹងទៅជញ្ជូនពីនឹងយកទៅដាក់ក្រោយទៀត ។

ឈុនលី ៈ តែកុមារអាយុ១៦ពូថា?

យឿន ៈ ទេ! អាយុ១៦ ១៧ តែបើថាធំគេបញ្ចេញ ។

ឈុនលី ៈ ហើយដល់ពេលធ្វើការនៅប៉ុន្មានឆ្នាំ ហើយធ្វើអីទៀត?

យឿន ៖ ទេ! ក្មេងៗអស់ហើយណា វាយូរហើយ ។ កាលនឹងចេញពីនឹងមក ចេញពីនឹងមកនៅជាមួយនារសាៗគេនៅបានប៉ុន្មានខែបានចេញមើលវា នៅជាមួយនារសាគេមិនអីទេ តែគ្រាន់ថាយើងវាពិបាកដើរតាមគេ ។

ឈុនលី ៖ នៅជាមួយនារសា?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ម៉េចបាននៅជាមួយនារសា?

យឿន ៖ ចុះគេកម្មាភិបាល ដូចជាភូមិគេមានអ្នកដើរតាមមួយឈ្លប ។

ឈុនលី ៖ អ្នកនារសា?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ តែពូម៉េចបានទៅនៅជាមួយគេ?

យឿន ៖ ចុះបើគេជ្រើសរើសៗទៅនៅជាមួយ ថាគេចង់បានអ្នកណា គេសុំស្នើតាមរយៈតាមមេនៅនេះមេកុមារនឹង ។

ឈុនលី ៖ ហើយមេភូមិនៅនេះអ្នកណាគេ?

យឿន ៖ ទេ! មេភូមិនឹងឈ្មោះអីទេ វាភ្លេចបាត់ទៅ នៅភូមិដូចឈ្មោះចាន់ចឹង យូរហើយវាភ្លេច ។

ឈុនលី ៖ ហើយនៅជាមួយនារសាគេនឹង ធ្វើអីខ្លះទៅ រត់សំបុត្រ រត់អីគេម៉េច?

យឿន ៖ ហ្នឹងហើយ ស្រេចតែគេត្រូវការ យកសំបុត្រទៅភូមិនេះចឹងទៅៗ ថាទៅ ។

ឈុនលី ៖ ទៅឆ្ងាយៗទេ?

យឿន ៖ ទេ!មិនជាឆ្ងាយ ពីភូមិមួយទៅភូមិមួយ ។

ឈុនលី ៖ តែនៅក្នុងស្រុកដដែលទេ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ កណ្តាលស្ទឹង?

យឿន ៖ អត់មានទៅណាឆ្ងាយទេ ។

ឈុនលី ៖ ហើយចុះរួចពីនឹងទៀត ម៉េចទៅ?

យឿន ៖ រួចពីនឹង គឺចេញពីនឹង កាលនឹងបេទម្នាក់ៗខ្ញុំរត់ៗមកនៅជាមួយឪពុកវិញ ។

ឈុនលី ៖ ហ្នឹងឆ្នាំណា?

យឿន ៖ ឆ្នាំ៧២នៅកន្លែងអគ្គភាពនឹង ដល់ពេល៧៣ ។

ឈុនលី ៖ នៅជាមួយខាងនារសា?

យឿន ៖ ៧៣អឺ!ក៏នៅជាមួយនារសា តែនៅបានប៉ុន្មានប្រហែលជា២ខែរត់មកនៅជាមួយឪពុកដែរ ឪពុកនេះក៏អាបេទម្នាក់...។

ឈុនលី ៖ បងប្អូននាក់?

យឿន ៖ មាន២នាក់ ប្រុសទាំង២ ។

ឈុនលី ៖ ចុះបង១ហើយប្អូនពូ?

យឿន ៖ បង ។

ឈុនលី ៖ គាត់ធ្វើអី កាលនឹង?

យឿន ៖ ទេ! បងអត់ដឹងបែកគ្នាតាំងពីនឹងមក ។

ឈុនលី ៖ បែកពីពេលណាមក?

យឿន ៖ បែកតាំងពីឆ្នាំ៧០ហ្នឹងមក អឺ!៧២ ។

ឈុនលី ៖ ចុះឥឡូវគាត់នៅណា?

យឿន ៖ ឥឡូវនៅផ្ទះនោះ នៅកណ្តាលស្ទឹង នៅជិត ។

ឈុនលី ៖ ស្រុកកំណើតដដែល?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ពូថារត់មកនៅជាមួយឪពុកនឹង ម៉េចបានមកនៅនឹង?

យឿន ៖ ចុះបើយើងវានៅនេះដូចជាអារម្មណ៍វាអត់មូល វានឹកបងនឹកឪពុក ក៏ដាច់ចិត្តរត់ៗបានម៉ាយប់២ចឹង គេទៅតាមយកមកវិញ យកមកតាមវិញ គេមកៗយើងមកវិញចឹងរត់ទៅវិញ វាដូចថាគោលបំណងយើងវាអត់ ។

ឈុនលី ៖ អត់ទាន់លះបង់ ផ្ទះបាន?

យឿន ៖ ហ្នឹងហើយ ចុះយើងនៅម្យ៉ាងបើយើងនៅកុមារវាក្មេងៗវាច្រើនៗ វាអាចឡប់អារម្មណ៍យើង ។

ឈុនលី ៖ ដល់នៅជាមួយនារសា គ្នាតិច?

យឿន ៖ ដល់នៅជាមួយគេនោះ ម្យ៉ាងគេប្រើយើងវាតូច ។

ឈុនលី ៖ និយាយទៅពូធ្វើនារសាផ្ទាល់ម៉ង?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ហើយដល់ពេលចឹងម៉េចទៅ ពេលគេហៅទៅវិញ?

យឿន ៖ ហៅទៅវិញមានអីទៅៗ ។

ឈុនលី ៖ ទៅនឹងគេ?

យឿន ៖ ហ្នឹងហើយ ទៅៗក៏គេលួកល្មើនទៅ ដល់ក្រោយឡើងនឹកក៏អន្តុយយំម្នាក់ឯងនឹក ខ្ញុំក៏ដាច់ចិត្តរត់មកទៀត វាលែងខ្លាច គ្មានខ្លាចខ្មោចស្អីទេ លែងខ្លាចលែងអីហើយ ឲ្យតែបានដល់ផ្ទះ តែវាមិនឆ្ងាយផងផ្ទះ ។

ឃុនលី ៖ នៅជិតនឹងដែរ?

យឿន ៖ ហ្នឹងហើយ ភូមិមួយទៅភូមិមួយ ។

ឃុនលី ៖ ពូដឹងទេ អាសំបុត្រដែលរត់នឹង អីគេៗនិយាយពីពូដឹង?

យឿន ៖ អឺ! យើងម៉េចដឹង ។

ឃុនលី ៖ នារសាគេ?

យឿន ៖ ហ្នឹងហើយ ហ៊ានតែនឹងរឿង ។

ឃុនលី ៖ មើលទៅសំងាត់ទេ? គេដូចឲ្យយើងទៅសំងាត់លាក់លៀម?

យឿន ៖ ទេ! សំបុត្រគេឲ្យមកវាមានស្រោមមានអីគេបិទជិត ។

ឃុនលី ៖ ហើយយើងទៅធម្មតា មិនមែនយើងលួចទៅ ពេលណាស្ងាត់អីអត់?

យឿន ៖ អឺ! អត់ទេ ធ្វើធម្មតា មិនទៅលួចអីទេ ។

ឃុនលី ៖ ចុះដល់ពេលខ្ទង់៧៨អីនោះ បន្ទាប់មកទៀតនោះ?

យឿន ៖ ទេ! ៧៨កាលនឹងខ្ញុំមិនដឹងនៅណាទេ ៧៨យូរហើយវាភ្លេចបាត់ហើយ តែបើថា៨១អានឹងយើងមកនៅនេះ បញ្ជូនមកនៅនេះវិញហើយ កាលនឹងអូ!ដូច៧៥ ។

ឃុនលី ៖ ចុះដូចក្នុងកំឡុង៧៥នោះ ដល់ពេលយើង?

យឿន ៖ ខ្ញុំ៧៥ក៏នៅ ។

ឃុនលី ៖ ដល់ពេលគេច្បាំងឈ្នះអីចឹង?

យឿន ៖ គេច្បាំងឈ្នះ អានឹងគេយកមកធ្វើនារសាវិញទៀតហើយ ដល់ពេលនេះ៧៥ ៧៦មកនៅគេបញ្ជូនមកនៅភ្នំពេញ ។

ឃុនលី ៖ ៧៦?

យឿន ៖ បាទ!

ឃុនលី ៖ ម៉េច អ្នកណាអ្នកបញ្ជូនមក?

យឿន ៖ ខាងតំបន់គេនឹង មកទាំងអស់ម៉ង មកទាំងតំបន់ មកទាំងអីទាំងអស់ ។

ឃុនលី ៖ គេថាម៉េចបានបញ្ជូនមកចឹង?

យឿន ៖ ទេ! រឿងរ៉ាវគេអត់មាននិយាយអីទេ តែមកនឹងមកនៅក្រសួងការបរទេសនៅបោសគ្រាន់តែបោសផ្ទះបោសសំបែង ។

ឈុនលី ៖ បោសសំអាត?

យឿន ៖ បាទ! នៅបោសសំអាតរើរៀបចំ វាមានជួនកាលចូលទៅខាងក្រោមផ្ទះនឹងមានឃើញខ្មោច ឃើញស្អីនៅក្នុងឃើញស្អុយឡើង ។

ឈុនលី ៖ ក្រសួងការបរទេសម៉េចក៏មានសព?

យឿន ៖ ហ៎! កាលសង្គ្រាមដូចចំការមនអីនេះ សុទ្ធតែនឹងដេកមិនស្រួលដេកអត់បានទេ លង់អាផ្ទះចំការមនស្គាល់ទេ ។ ស្គាល់ហើយនៅភ្នំពេញ ។

ឈុនលី ៖ ផ្ទះចំការមន បើចំការមនខ្ញុំស្គាល់ ប៉ុន្តែផ្ទះមិនដឹងមុំណា?

យឿន ៖ អាផ្ទះអន្លាញ់ៗនឹង ផ្ទះកន្លែងលន់ នល់នៅនោះនឹងសម្រាប់ភ្ញៀវ ។

ឈុនលី ៖ ផ្ទះលន់ នល់?

យឿន ៖ ផ្ទះលន់ ណុន ។

ឈុនលី ៖ លន់ ណុន?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ លន់ ណុននឹងអ្នកណាគេ មិនមែន លន់ នល់?

យឿន ៖ លន់ នល់ បងលន់ ណុន ។

ឈុនលី ៖ ហើយលន់ ណុន គាត់ធ្វើអីគេ?

យឿន ៖ ទេ! មិនដឹងតែផ្ទះនឹងក៏មានយន្តហោះចុះពីលើដែរ អាដំបូងផ្ទះនឹងវាមានអាង គេចាក់អាងដីខ្សាច់ គេចាក់អាងពីលើនឹងចុះការពារគ្រាប់ផ្លោង ហើយយន្តហោះមកក៏អាចចុះពីលើនឹងបាន ។ តែព្រលានកន្លែងលន់នល់នោះ អានឹងព្រលានធំ ។ តែខ្ញុំមិនដែលឃើញទេណា លន់នល់អីនេះទេ តែគ្រាន់ថាខ្ញុំគេបញ្ជូនទៅបោស ។

ឈុនលី ៖ បោសផ្ទះៗនឹងលន់ ណុននឹង?

យឿន ៖ ហ្នឹងហើយ ផ្ទះនឹងសម្រាប់ភ្ញៀវ ផ្ទះនឹង ។

ឈុនលី ៖ ប៉ុន្តែអានឹងដល់ពេល អានឹងឆ្នាំ៧៦ពូ ចូល៧៦?

យឿន ៖ បាទ! ៧៦ ៧៧ ។

ឈុនលី ៖ ចឹងហើយលន់ ណុននឹង គាត់ខាងសាធារណរដ្ឋ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចឹងបានន័យថាគាត់ចេញអស់ហើយ?

យឿន ៖ ចេញហើយ ។

ឈុនលី ៖ នៅតែផ្ទះទេ?

យឿន ៖ ហ្នឹងហើយនៅតែផ្ទះទេ ។

ឈុនលី ៖ ហើយផ្ទះនឹងគេយកធ្វើអី?

យឿន ៖ ផ្ទះនឹងគេសម្រាប់ដាក់ភ្ញៀវបរទេស ។

ឈុនលី ៖ ហើយអ្នកណាអ្នកគ្រប់គ្រងនៅផ្ទះនឹងទៀត?

យឿន ៖ ទេ! គ្រប់គ្រងមានអ្នកណាគេ បងចៀម ហើយបងហុង តែមេៗខ្ញុំស្គាល់មិនអស់ទេ ។

ឈុនលី ៖ ចុះដូចពូនៅក្រសួងការបរទេសចឹង អ្នកណាគេអ្នកដឹកនាំក្រសួងនឹង?

យឿន ៖ ក្រសួងមានតែបងហុង ។

ឈុនលី ៖ ជារដ្ឋមន្ត្រីម៉ង?

យឿន ៖ ទេ! រដ្ឋមន្ត្រីមិនដឹងពីអ្នកណា បើខ្ញុំមិនសូវស្គាល់ទេ ។

ឈុនលី ៖ ចុះហុងនឹងគាត់ធ្វើអីគេ?

យឿន ៖ បងហុងនឹងគាត់ក្តោបក្តាប់កន្លែងអ្នកសំអាត អ្នករៀបចំផ្ទះនឹង ។

ឈុនលី ៖ ហើយបោសសំអាត ហើយមានទៅណាទៀត?

យឿន ៖ អត់ទេ អត់មានទៅណា អានឹងវាមានផ្នែកវា ។

ឈុនលី ៖ អត់មានទៅធ្វើការអីផ្សេងទៀត ហើយយើងបោសសំអាតប៉ុន្មានឆ្នាំ?

យឿន ៖ ហ្នឹងបោសនៅសំអាតផ្ទះទាល់ លុះថាមានភ្ញៀវចិនមានកូរ៉េពីណាចឹង ធ្វើការជប់លៀង២ថ្ងៃ
គេប្រាប់ឲ្យសំអាតហើយ បោសក្រោមបោសលើ ជូតដាំផ្កាអីចឹងទៅ ។

ឈុនលី ៖ និយាយទៅកន្លែងនឹងទទួលភ្ញៀវចិន?

យឿន ៖ ទេ! មិនថាចិន កូរ៉េ វៀតណាមស្អីទេ លាវក៏ទៅបានឲ្យតែភ្ញៀវបរទេស ។

ឈុនលី ៖ ហើយគេខស្សាហ៍មក?

យឿន ៖ ទេ! យូរៗមកម្តង ។

ឈុនលី ៖ បើគេអត់មកយើងធ្វើការអី?

យឿន ៖ អត់មកកនៅតែសំអាតធ្វើម៉េច កុំឲ្យមានសំបុកពីងពាង កុំឲ្យមានសំរាម តែនេះគេដើរ ។

ឈុនលី ៖ មានច្រើនទេពូ អ្នកបោសសំអាត?

យឿន ៖ ទេ! ច្រើនដឹង ។

ឈុនលី ៖ ប្រហែលប៉ុន្មាននាក់?

យឿន ៖ ១០នាក់២០នាក់ ចុះផ្ទះវាច្រើនរាប់រយខ្នង ហើយផ្ទះនឹងមុខទីធ្លាធំដែរនឹង... ។

ឈុនលី ៖ ឈ្មោះហុងនឹងស្រី ហើយប្រុស?

យឿន ៖ ប្រុស ។

ឈុនលី ៖ ហើយពូនៅបោសសំអាតដល់ឆ្នាំណា?

យឿន ៖ ទាល់តែបោសសំអាតទាល់តែវៀតណាមចូល ។

ឈុនលី ៖ ៧៩?

យឿន ៖ បាទ!

ឈុនលី ៖ ចុះពេលវៀតណាមចូលនឹង ស្ថានភាពម៉េចខ្លះទៅ?

យឿន ៖ ទេ! ចូលនឹងវាមានមុននឹងចូលវាមាន...វាមានតិចផុសនេះ តិចផុសនោះ ហើយកន្លែងដែលផ្ទះកុមារសង្គ្រោះនោះ ។

ឈុនលី ៖ កុមារសង្គ្រោះ?

យឿន ៖ ហ្នឹង កុមារនឹងនៅមាត់ទន្លេនឹងដែរ តិចបាត់នេះ តិចឃើញលួចនេះ តិចបាត់នោះ តិចបាត់ឆ្នាំង តិចបាត់អង្ករ ។

ឈុនលី ៖ ម៉េចចឹង?

យឿន ៖ ហ្នឹង មិនដឹង ហើយអាមាត់ទន្លេៗបួនមុខ តិចផុសនេះតិចផុសនោះ ហើយផ្អើលៗដាប់ ហើយខ្ញុំអត់ទេ នៅ ។

ឈុនលី ៖ ចឹងពេលណាបានគេឲ្យចេញមក?

យឿន ៖ ដល់ពេលដែលថារៀបផ្ទុះហើយ បានចាប់ផ្ដើមឲ្យចេញៗមកមានអីខ្លះក៏រត់បានទៅដល់ផ្ទះទៅ ។

ឈុនលី ៖ ពូបានទៅផ្ទះដែរ?

យឿន ៖ អត់ ទៅណាបើមិនស្គាល់ដឹងផ្លូវខ្មែរខ្វាចចេះ ។

ឈុនលី ៖ ចឹងចេះមកតាមគេ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ហើយគេប្រាប់ថាម៉េចពេលមក?

យឿន ៖ ពេលមកចេះមកៗ រត់ឡើងភ្នំចុះភ្នំ ។

ឈុនលី ៖ ជិះអីគេមក?

យឿន ៖ ជិះស្អីដើរ ។

ឈុនលី ៖ ដើរ?

យឿន ៖ ដើររាប់ខែ ដាច់បាយដាច់ទឹក ។

ឈុនលី ៖ ពីអាចរៀបរាប់និយាយបានទេ ស្ថានភាពពេលមកនឹងឃើញអីខ្លះ ឃើញដែលគេកើតឡើងខ្លះតាមផ្លូវ?

យឿន ៖ ទេ! អារឿងតាមផ្លូវមកនឹងវាមានជួនកាល របៀបថាកាលនឹងប្រើពាក្យគិញ ជួនកាលយប់មានក្របីពាក់ត្រដោក តែក្របីមិនមែនក្របីទេ មនុស្សទេណា ។

ឈុនលី ៖ ម៉េចចឹង?

យឿន ៖ ពាក់ត្រដោកចុះវាតាមដានយើង តាមដានពាក់ត្រដោកប្លុកទៅស្រង់នឹងតាមដានហៅគ្រាប់ឡោងដាក់ តែអានឹងនេះ ខាងវៀតណាមគ្រាប់ឡោងដាក់ ប្រើកាំភ្លើងសម័យ ភាសាគេមិនដឹងប្រើពាក្យស្អី ។

ឈុនលី ៖ ហើយអត់បាយអត់ទឹកចឹង?

យឿន ៖ ហឺ! ។

ឈុនលី ៖ គ្នាច្រើន ប៉ុន្មាននាក់ទៅ?

យឿន ៖ ហឺ! រាប់ពាន់ ទាំងប្រជាជន ទាំងកូនក្មេងរញ៉េរញ៉ៃ ខ្លះក៏មានសម្រាលតាមព្រៃក៏មាន ។

ឈុនលី ៖ ចុះគេមានបែកទៅណាទៀតទេ ម៉េចបានមកតែខាងនឹង ពេលចេញមកនឹង គេមានចេញទៅកន្លែងផ្សេងៗទៀត?

យឿន ៖ មាន ជួនកាលវារត់តាម អានឹងវាមានបែកគ្នាថាទៅចេះទៅក្រែងលរបានប៉ះដំឡូងប៉ះអី ខ្លះ ...... ហើយវាមានតាមផ្លូវវាមានស្លាប់ច្រើនដែរនឹង ។

ឈុនលី ៖ ស្លាប់ដោយសារអត់បាយ?

យឿន ៖ ហ្នឹងហើយ ជាពិសេសអូរអន្ទក់នេះ ។

ឈុនលី ៖ នៅណាពូ?

យឿន ៖ អូរអន្ទក់យើងនេះ ។

ឈុនលី ៖ អូរអន្ទក់?

យឿន ៖ បាទ! សាស្ត្រា ទៅដងទឹកផ្កាប់មុខ ។

ឈុនលី ៖ ម៉េចចឹង?

យឿន ៖ ចុះវាអត់បាយ ខ្លះដេកនៅអង្រឹង ។

ឈុនលី ៖ រឹងស្លាប់?

យឿន ៖ ហើយកូននៅបៅលើអង្រឹង ហើយម្ដាយដាច់ខ្យល់ ដាច់ដង្ហើមបាត់ហើយ ខ្លះក៏ស្រក់ទឹករងែស្រក់ទៅលើអង្រឹង ខ្លះនៅខ្ទមៗអត់មានស្បូវអីប្រក់ទេ ប៉ុនខ្ទមកាច់មែកឈើដូចស្នាចឹងគ្រាន់ថាវាមិនឡើងដេកលើដីបួលដូចស្វា ដេកក្រែនឹង ។

ឈុនលី ៖ ចុះសាស្ត្រានឹង អានឹងនៅក្នុងតំបន់អីគេសាស្ត្រានឹង?

យឿន ៖ ទេ! តំបន់ៗអីគេ នេះនៅសាស្ត្រានៅអូរអន្ទក់នេះ កាប៊ីន ។

ឈុនលី ៖ អានឹងភូមិ ស្រុកអីគេ?

យឿន ៖ ហ៎! ដូចសំពៅលូន ។

ឈុនលី ៖ ចឹងពូមកនឹងកាត់តាមបាត់ដំបង សំពៅលូនមក?

យឿន ៖ បាទ!

ឈុនលី ៖ ដើររហូត?

យឿន ៖ ដើរ ជួនកាលវាមានឡានជិះខ្លះដែរ ជួបឡានគេដឹកបាយដឹកអីទៅ ដឹកគ្រាប់ដឹកអី ។

ឈុនលី ៖ ម៉េចទៀតទៅពូ អីគេសាស្រ្តានឹង ដូចឃើញស្លាប់ច្រើន?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ កាលនឹងអ្នកណាដឹកនាំឲ្យរត់មកនឹង?

យឿន ៖ អឺ! លែងហើយលែងស្គាល់មានអ្នកដឹកនាំមិនដឹកនាំហើយ តាមគ្នាហើយ អ្នកណាមកច្រើន មកតាមគ្នាហើយ មេដោយមេកូនដោយកូនហើយមិនដឹងណាណែទេ ។

ឈុនលី ៖ ប៉ុន្តែពូមកដូចមកជារបៀបអន្តភាពកាលលើកមុននោះ?

យឿន ៖ មកមុនដំបូងបង្កើតជាអន្តភាព ទល់ក្រោយទៅ វាដាច់បាយដាច់ទឹក សូម្បីតែធាងត្រាវនឹង មកចំធាងត្រាវនឹងក៏លែងរមាស់អស់ហើយ ។

ឈុនលី ៖ ចេះតែហូបទៅ អត់ដឹងរមាស?

យឿន ៖ ហ្នឹងហើយកាត់បបរ ប៉ះរត់ចុះរត់ឡើងនឹងរត់តាមភ្នំណា មកដល់កន្លែងនឹងគេហៅស្ទឹទេមក ចំជង្រុក ឃ្លាំងគេដាក់សម្រាប់គេលាក់យកទៅសមរភូមិ ស្បៀង ដូចជាអំបុក តែដឹង ។

ឈុនលី ៖ មានអំបុក?

យឿន ៖ ហ្នឹងហើយ អំបុកទាំងឃ្លាំង ។

ឈុនលី ៖ ឃ្លាំង តាមពិតស្បៀងនឹងគេយកទុកឲ្យអ្នកណា?

យឿន ៖ ទុកឲ្យទ័ព ។

ឈុនលី ៖ ទ័ពដែលយើងរត់មកនឹង យើងរត់មកជាមួយគេ?

យឿន ៖ អត់ទេ គេលាក់សម្រាប់ទុកទ័ពគេថាបើកយុទ្ធនាការនឹង ទៅសមរភូមិនឹង ដល់ហើយទៅគេ មកបើក ប្រជាជនដល់មកចំហើយដែលឃាត់ឈ្នះ ទៅគាស់ចាប់ផ្តើមយកដាក់ថ្នក់ដាក់អីនឹង យកក្រណាត់ដេរធ្វើថែស្ពាយ ដាក់អន្តរស្ពាយ ដាក់ញាត់ៗបានអានឹង..... ។

ឈុនលី ៖ វេទនា ពិបាកខ្លះ?

យឿន ៖ តែវាមិនដល់ដូចកាលយើងនៅនេះ ។ យើងនៅលើភ្នំ អូ! ។

ឈុនលី ៖ ភ្នំអីគេ?

យឿន ៖ ភ្នំរាំង ។

ឈុនលី ៖ ទាហាននៅលើភ្នំរាំង?

យឿន ៖ ហ្នឹងហើយ និយាយពីអំបិលក៏ អឺ!ពិបាកមើល និយាយពីខ្មៅ ហើយអន្តរជន្តូវត្រីផាត់ត្រីអឺ សុទ្ធតែជន្តូវ... ។

ឈុនលី ៖ អានឹងដោយសារអត់មានអីហូប?

យឿន ៖ ទាហានគេ ហ្នឹងហើយបើអត់នឹងហើយ ។

ឈុនលី ៖ ហើយដល់ពេលធ្វើដំណើរមកទៀតអីចឹង ចុះពូមានដឹងទេថាតំបន់នេះមុនដំបូងគេហៅស្រុកអីគេ?

យឿន ៖ ទេ! ខាងនោះអត់ដែលដឹង ដល់មកចាប់ផ្ដើម ។

ឈុនលី ៖ ចុះគេហៅអីគេចុះតំបន់នឹងស្រុកម៉ាឡៃនឹង?

យឿន ៖ នេះៗវាអត់ដឹង វាអត់ស្គាល់កាលនឹង ។

ឈុនលី ៖ ចុះពេលមក ធម្មតាយើងមកដល់កន្លែងមួយអីចឹង យើង?

យឿន ៖ មកមានមនុស្សណាអត់ សុទ្ធតែព្រៃនឹង ។

ឈុនលី ៖ គេហៅតាមព្រំដែន?

យឿន ៖ ហ្នឹងហើយ តាមព្រំដែន ជាប់ព្រំដែនជាប់ព្រំដែននេងពឹននេះ កាលនឹងមកនៅនឹងយូរដែរហើយ ។

ឈុនលី ៖ ចុះពូពេលមកដល់តំបន់នឹងភ្លាម នៅណា នៅកន្លែងទីតាំងណាមួយ?

យឿន ៖ ទេ! នៅខ្ទង់រាប់នោះ អានឹងនៅគ្នាច្រើន ។

ឈុនលី ៖ ហើយយើងធ្វើអីចឹង?

យឿន ៖ ទេ! អានឹងយើង អឺគេត្រូវការជញ្ជូនបាយ ជញ្ជូនទឹកអីទៅសមរភូមិយើងចេះ ។

ឈុនលី ៖ សមរភូមិគេត្រឹមណា តំបន់មួយណាសមរភូមិគេ?

យឿន ៖ ដូនកាលទៅស្វាយនោះ ។

ឈុនលី ៖ សមរភូមិនឹងប្រយុទ្ធជាមួយខាង វៀតណាម?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចឹងពេលនឹងវៀតណាមគេដេញមកតាមក្រោយរហូត?

យឿន ៖ ហ្នឹងហើយ ដល់ក្រោយឡើងវៀតណាមមកវ៉ៃនេះបាន តែអានឹងយើងចេញមករាយគ្នាមានផ្ទះនៅធ្វើផ្ទះធ្វើអីនេះបាន មានសារតាំងកន្លែងសម្ដេច ។

ឈុនលី ៖ សារតាំង អានឹងគេប្រើធ្វើអីគេ?

យឿន ៖ ទេ! ពេលសម្តេចមកម្តងម្កាលស្នាក់នៅនេះ ។

ឃុនលី ៖ គាត់ជួបជាមួយអ្នកណាគេ សារគាំង បើនៅព្រំដែនចិន ជួបថៃ?

យឿន ៖ ទេ! ថៃក៏ទៅជួបៗ មេយើងនៅនឹងក៏ជួប មេខ្មែរក្រហម ។

ឃុនលី ៖ អ្នកណាអ្នកមេតំបន់នឹង?

យឿន ៖ អឺ! វាស្គាល់មិនច្បាស់ៗ បានពិបាកនិយាយ បើយើងស្គាល់វាមិនច្បាស់ ។

ឃុនលី ៖ ចុះពូនៅជញ្ជូនស្បៀងនឹងដល់ពេលណា?

យឿន ៖ គេ ទាល់តែគេត្រូវការបានចាប់ផ្តើមជញ្ជូនទៅ ។

ឃុនលី ៖ ហើយចុះបន្ទាប់ពីនឹង មានទៅណាទៅណែទៀតអត់?

យឿន ៖ ទេ! មានតែស្អីមកវិញនឹង ដល់ពេលយើងជញ្ជូនប្រគល់ឲ្យគេសម្រេចហើយ យើងត្រឡប់មកវិញ មានកាប់អុសដុតធ្យូងអីចឹងទៅ ។

ឃុនលី ៖ ចុះមកដីបូងសុទ្ធតែព្រៃ ប៉ុនពិបាកទេពូ ពិបាកខ្លាំង?

យឿន ៖ យី! នេះតំបន់ចាញ់ ។

ឃុនលី ៖ ហើយចឹងស្លាប់មនុស្សច្រើន?

យឿន ៖ ទេ! រឿងស្លាប់នេះមិនសូវប៉ុន្មានដែរទេ មិនដូចខ្ញុំការរត់នោះទេ ។

ឃុនលី ៖ ការសាស្រ្តា?

យឿន ៖ អឺ!

ឃុនលី ៖ ពេលមកដល់ភ្លាមអត់សូវចាញ់ទេ?

យឿន ៖ យី! ដូចថាអ្នកដេកថ្ងៃ តែក្រោកឡើងសុទ្ធតែឈឺក្បាលហើយ ។

ឃុនលី ៖ អានឹងម៉េចចឹងពូ ចាញ់នឹងមកពីអី?

យឿន ៖ មិនដឹង តែថាក្រោមនេះសុទ្ធតែភ្លីចិញ្ច្រាចហើយ ។ ខ្ញុំវាចាំមិនបានវែងឆ្ងាយ ។

ឃុនលី ៖ តែពីថាចាញ់អីនោះ ដូចក្មេងៗតូចៗអីចាញ់ច្រើន?

យឿន ៖ ចាញ់វាមានពេទ្យៗគេព្យាបាលថ្នាំមកពី ថាសង្រ្គាម ថ្នាំគ្រុនចាញ់គេពូកែដែរនឹង ។

ឃុនលី ៖ ចុះគ្រាន់ពេលរត់មកតាមផ្លូវនឹង មានពេទ្យមានអីត្រឹមត្រូវរបស់គេដែរ?

យឿន ៖ មានៗតើ ។

ឃុនលី ៖ គេបង្កើតជាម៉េច ជាក្រុម ជាអង្គភាព?

យឿន ៖ ទេ! ពេទ្យដូចតាមជាអង្គភាពគេនឹង ។

ឃុនលី ៖ ហើយពូនៅក្នុងអង្គភាពអីគេ?

យឿន ៖ កាលនឹងវាថាចូលក្នុងលក្ខណៈទ័ពដែរ តែទ័ពនឹងខាងអឺគ្រាន់ជញ្ជូនស្បៀងជញ្ជូនអីគេ ។

ឈុនលី ៖ ខាងជីកជញ្ជូន?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ អានឹងឆ្នាំណា ដែលពូចូលខាងជញ្ជូនស្បៀងជញ្ជូនអី?

យឿន ៖ ទេ! អានឹងចាប់ពីឆ្នាំ៨០ ៨១មករហូត ហើយយើង....។

ឈុនលី ៖ ដល់ពេលនៅចឹងទៅមានរឿងកើតឡើងទៀត?

យឿន ៖ ដូចមិនមានអី រឿងកើតឡើងស្រេចតែមេៗគ្នាគេនោះទេ ។

ឈុនលី ៖ ដូចច្បាំងគ្នាអី?

យឿន ៖ អូ! ច្បាំងគ្នាយើងមានអី គ្រាន់នេះហៅជំនួយជញ្ជូនទឹកជញ្ជូនបាយទៅគេទប់ទល់នៅមុខទៅ ជួនកាលគេហៅយើងទៅជួយគេនោះទៅ តែជួយនឹងក្នុងទ្រូងក្ដុកក្ដួះអារម្មណ៍វាគិតមកៗនេះ អ្នកប្រយ័ត្នប្រយែង ។

ឈុនលី ៖ ចឹងពូមានគ្រួសារនៅណា?

យឿន ៖ នេះមាននៅខ្វាវាប់ ។

ឈុនលី ៖ ឆ្នាំណា?

យឿន ៖ ទេ! ឆ្នាំប៉ុន្មានទេ កាលនោះ...។

ឈុនលី ៖ ៨០នៅ?

យឿន ៖ កាលនោះបែបដាង៨០ហើយ ។

ឈុនលី ៖ ៨៣ ៨៤ការ?

យឿន ៖ អឺ!

ឈុនលី ៖ ការចឹង ការរបៀបដូចការនៅក្នុង កាលជំនាន់៣ឆ្នាំ ក្នុងកំឡុង៧៥ ៧៩ របៀបការច្រើន គូ ឬមួយក៏?

យឿន ៖ ហ្នឹងហើយ តែអានេះយើងការសម័យនឹងគេការហៅថាចាប់ដៃគ្នា ។

ឈុនលី ៖ តែគ្នាការច្រើនទេកាលពូការ?

យឿន ៖ អត់ទេ ខ្ញុំតែម៉ាគូនឹង តែវាមានដូចថាមេៗដូចជាកងវរៈ ។

ឈុនលី ៖ កងវរៈពូឈ្មោះអីទៅ?

យឿន ៖ ប្រាប់ទៅក៏ ឈ្មោះយឹម ។

ឈុនលី ៖ ឈ្មោះយឹម?

យឿន ៖ តែត្រូវគ្រាប់ស្លាប់បាត់ហើយ ។

ឈុនលី ៖ ចុះមានអ្នកផ្សេងទៀត?

យឿន ៖ អ្នកផ្សេងទៀត មានលោកសុខ ភាព នឹងទទួលចាប់ ។

ឈុនលី ៖ គាត់ឡើងធំហើយ?

យឿន ៖ ហ្នឹងឡើងធំហើយ ។ ស្គាល់ដែរតើ?

ឈុនលី ៖ ចាំ! ពូឈ្មោះអ៊ីចឹង ។ ចឹងអ្នករត់មកគ្រប់គ្រងដោយលោកសុខ ភាពនឹងឯង?

យឿន ៖ បាទ! កាលនឹងគាត់ខាង គាត់កាន់កងពលទេ ។

ឈុនលី ៖ កងពលលេខប៉ុន្មាន?

យឿន ៖ ទេ! មិនដឹងលេខប៉ុន្មានទេ ភ្លេចបាត់ហើយ ដល់ចឹងវាលែងយកចិត្តទុក ខ្ញុំវាដាច់អង្គភាពនឹង យូរហើយ ។

ឈុនលី ៖ ហើយចុះដល់ពេលការហើយចឹង យើងនៅធ្វើការដូចធម្មតាចឹងទៅ?

យឿន ៖ អត់ទេ នៅជំរំ។ តែនៅជំរំបានប៉ុន្មាន ការជំរំនឹង ការហើយបានប្រហែលជាម៉ាខែ ឬកន្លះខែ ។

ឈុនលី ៖ ការនៅជំរំ?

យឿន ៖ ហ្នឹង ។

ឈុនលី ៖ ៨៤?

យឿន ៖ អឺ! ការជំរំ ។

ឈុនលី ៖ អត់ទេ និយាយថាពូការ ឆ្នាំប៉ុន្មាន៨៤?

យឿន ៖ កាលនឹង៨៤ ។

ឈុនលី ៖ ភ្លេចហើយ?

យឿន ៖ មិនដឹងប៉ុន្មានទេ ។

ឈុនលី ៖ អូ! ចុះទៅជំរំឆ្នាំណា?

យឿន ៖ អាកាលនឹងដែលងអ៊ុកឡុកដែលវៀតណាមដេញមកនោះ ដេញមកយើងមិនចូលដីថៃ ។

ឈុនលី ៖ ចាំ! ដេញមកភ្នាម ចូលដីថៃភ្នាម?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ មកម៉េចកើត?

យឿន ៖ អឺ!

ឈុនលី ៖ ដេញមកភ្នាមក្រែង៧៩?

យឿន ៖ អឺ! អត់ទេ អា៧៩យើងនៅនោះទេ នៅភ្នំពេញនោះ ។

ឈុនលី ៖ អាពេលគេជម្លៀសមកពេលវៀតណាមចូលមិន៧៩?

យឿន ៖ ហ្នឹងហើយតែដល់ពេលអាមកនេះមិនមែន៧៩ណា ។

ឈុនលី ៖ ៨០ដាង?

យឿន ៖ ហ្នឹង ។

ឈុនលី ៖ ចុះពូទៅថៃនឹង ហ្នឹងដោយសារវៀតណាមចូលមកខ្លាំង?

យឿន ៖ ហ្នឹងហើយចុះបើដូចគ្រាប់ឡើងដូចជះអង្ករម ហើយមិនមែនតែឯងណា ដូចថារាប់ម៉ឺន ។

ឈុនលី ៖ ចុះកាលនឹងមានទ័ពណាខ្លះដែលនៅខាងតំបន់នឹង ខាងផ្នែកខាងណា ដូចមានតែខាងខ្មែរក្រហម ឬមួយក៏មានអ្នកណាទៀត?

យឿន ៖ វាចំរុះ ខាងក្នុងយើងនឹង ខាងស្អី ។

ឈុនលី ៖ សាធារណរដ្ឋ?

យឿន ៖ ហ៉េ! ចប់ហើយដុតហើយនឹងមកនេះដុត ខាងអឺ!មិនទាហានខាងកាលនឹងវៀតណាមមកហើយមកដល់នេះវៀតណាមមកហើយ ។ ចឹងបានថាមានបារ៉ែតមានអីនេះសុទ្ធវៀតណាមហើយ ។

ឈុនលី ៖ ចឹងបានន័យថាចូលមកដល់តំបន់នឹងហើយ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចឹងដាក់មីនដាក់អីខាងណាអ្នកដាក់ មានតែវៀតណាមទេ?

យឿន ៖ ទេ! វៀតណាមមកក៏ដាក់ ខាងខ្មែរក្រហមក៏ដាក់ កន្លែងនេះគេដាក់...... ។

ឈុនលី ៖ តំបន់អីគេ ឥឡូវនឹង?

យឿន ៖ ហ្នឹងហើយ អត់ទេ ឥឡូវយើងអស់ហើយ តែ ។

ឈុនលី ៖ ហ្នឹងហើយ ប៉ុន្តែឥឡូវនៅក្នុងភូមិឃុំអីគេ?

យឿន ៖ ហ្នឹងភូមិឃុំៗនឹង ស្រះនេះជិតនេះ តែកាលពីមុនកាលពីដើមមកគេថាស្រះខ្មែរសេរី តែខ្ញុំអត់ដឹងទេ ស្រះខ្មែរសេរី ស្រះនឹងពុគេនិយាយថាផ្ទុះថ្មផ្ទុះអីឃើញចាក់សាបទេ គេអត់មានឃើញទេ កាលនោះខ្មែរក្រហមក៏ដាក់ ខាងក្នុងប្រជាពលរដ្ឋក៏ដាក់ ។

ឈុនលី ៖ ហើយចុះបើគិតទៅចាប់ផ្តើមដាក់ឆ្នាំណា?

យឿន ៖ ទាល់សួរចឹងឆ្លើយដឹងដាក់ឆ្នាំណា ។

ឈុនលី ៖ អត់ចាំឆ្នាំ?

យឿន ៖ អត់បើទៅកន្លែង ។

ឈុនលី ៖ ប្រហែលៗ?

យឿន ៖ ទេ! គ្រាន់ថាមីនគេដាក់ជាប់ និយាយរួមទៅកន្លែងណាក៏ឃើញតែមីន ។

ឈុនលី ៖ តែពេលខ្មែរក្រហមមកភូមិនឹង អត់ទាន់ដាក់មីនទេ?

យឿន ៖ ដាក់ម៉េច យើងបានគ្រាប់ពីណា ។

ឈុនលី ៖ ដាក់មីននឹង ដាក់មុនពេលយើងទៅព្រំដែន ឬមួយក៏ក្រោយពេល អឺ!ទៅនៅថៃទៅនៅជំរំ?

យឿន ៖ ទេ! ទៅថៃ ទៅម៉ាគ្រានឹង ទៅម៉ាប្រហែលរយៈកន្លះខែ ឬក៏ម៉ាខែមកវិញ ។

ឈុនលី ៖ ខ្ទង់ឆ្នាំណាពូចាំទេ?

យឿន ៖ ទេ! មិនដឹងឆ្នាំណា មិនបានចាំ ។

ឈុនលី ៖ ៨០ដាង?

យឿន ៖ វាចូល៨០ដាងនឹងឯង តែមិនដឹង៨០ប៉ុន្មាន ។

ឈុនលី ៖ ៨៥អីអត់ ៨៥ឥឡូវ?

យឿន ៖ ដូចចូល៨៥ដឹង យើង ។

ឈុនលី ៖ ចុះពូមកវិញឆ្នាំណា ព្រោះនៅម៉ារយៈចឹង?

យឿន ៖ អឺ! ទៅមកៗចេះតែគេជូនបញ្ជោញៗ ចឹងឡានគេយកមក ។

ឈុនលី ៖ ចឹងបានន័យថាយើងទៅជំរំថៃមែន ប៉ុន្តែយើងនៅចេញចូលនៅនេះ?

យឿន ៖ បាទ!

ឈុនលី ៖ ដូចពូៗចេញចូលចឹងធ្វើអី នៅជញ្ជូនគ្រាប់ អីគេទៀត?

យឿន ៖ ជញ្ជូនគ្រាប់ជញ្ជូនអី ។

ឈុនលី ៖ តែពូអត់ទៅបាញ់នឹងគេទេ?

យឿន ៖ ទេ! រឿងទៅបាញ់ដល់ពេលនេះគេអូសទៅ តែទៅនឹងអឺបាញ់ធម្មតាទេ បើយើងមិនបាញ់ គេៗដាក់យើង តែគ្រាន់ថាបាញ់នឹងនឹកឃើញថាខ្មែរគ្នាឯង យល់ឃើញថាខ្មែរគ្នាឯង ។

ឈុនលី ៖ ចុះពេលនឹងបាញ់ជាមួយខ្មែរគ្នាឯង មិនមែនវៀតណាមទេ?

យឿន ៖ វៀតណាមក៏វៀតណាម អាខ្មែរក៏ខ្មែរ ។

ឈុនលី ៖ បើគិតទៅខ្មែរនឹងគេហៅក្រុមអីគេខាងនោះ ខាងក្នុង?

យឿន ៖ គេហៅ គ្រាន់តែហៅថាទាហានខាងក្នុង គេហៅទាហានខ្មែរ ។

ឈុនលី ៖ ដល់ពេលនេះគេហៅខ្មែរក្រហម?

យឿន ៖ ហ្នឹងហើយ មែនទែន នឹកឃើញខ្មែរក្រហម ហើយនឹងទាហានខ្មែរសុទ្ធតែខ្មែរគ្នាឯង ។ មែនទែនខ្ញុំប្អូនអាពេលសិក្សាចឹង ប្អូនមួយនៅឥឡូវមិនដឹងទៅនៅណាទេ នៅបាត់ដំបង ។ ដល់ពេលសុខសាន្តចឹងទៅវាជិះម៉ូតូដើររកខ្ញុំ ។ ដើររកគេវាសួរគេ មកដែលខ្ញុំវានិយាយរឿងសមរភូមិនៅអូរម៉ុងនេះ ហើយខ្ញុំគ្នាខ្មែរក្រហមគ្នា៦នាក់ ហើយវារថក្រោះអាប្អូននឹង ។

ឈុនលី ៖ ប្អូននឹងប្រុស?

យឿន ៖ ប្រុស ។

ឈុនលី ៖ ជីដូនមួយ ហើយក៏ម៉េច?

យឿន ៖ ជីដូនមួយ ។

ឈុនលី ៖ ហើយម៉េចទៀត?

យឿន ៖ ហើយវាទៅខាងរថក្រោះ ហើយមានមេកងពល វានៅរថក្រោះវាដាច់វាជាន់មីនៗកាដុង ៥លីត្រ កាដុងសចេះៗ ។

ឈុនលី ៖ មីនគេប៉ុននឹង?

យឿន ៖ មីនថ្មៃ អានឹងខ្លាំងជាងអាមីនអីទៀត ។

ឈុនលី ៖ មីនគោន?

យឿន ៖ ហ្នឹងហើយ ហ៎! វាមិនដល់មីនគោនទេ តែអានេះដាច់ៗប្រវ៉ាក់ ។

ឈុនលី ៖ ម៉េចទៀតទៅ?

យឿន ៖ ដល់ចឹងទៅវាដោះមើលៗវាជីកគ្រឡុងឲ្យកងពលនឹងនៅក្រោមរថក្រោះនឹង តែរថក្រោះនឹងថាខូចហើយបាញ់វាមិនងាយឆេះទេ ។

ឈុនលី ៖ ម៉េចចឹង?

យឿន ៖ មានអីបញ្ចេះ បើអត់ឆេះ តែបញ្ចេះបានមានចរន្តភ្លើងហើយយើងបាញ់មកវាប៉ះបានឆេះ

ឈុនលី ៖ ហើយគាត់មកនឹងមកបម្រុងរកពូ?

យឿន ៖ អត់ទេ កាលនឹងវៃគ្នា ដល់ពេលនេះមើលរថក្រោះ អាកាណុងកាំភ្លើងរថក្រោះវាសឹងតែដល់ចុះប្រវែងនឹងប្រវែងនឹងសឹងតែដល់ ។

ឈុនលី ៖ ប្រវែងផ្ទះនេះ?

យឿន ៖ ហ្នឹងហើយ ។ ហើយគ្នាខ្ញុំ៨នាក់ អាប្អូននឹង ។

ឈុនលី ៖ ៦ ហើយ៨?

យឿន ៖ អឺ! ៦ៗនាក់ ។

ឈុនលី ៖ ម៉េច?

យឿន ៖ ដល់ពេលម្នាក់នោះ គេរៀបដូចថាមេ អឺ!ចុះគេមេៗក្រុមហើយឯងដូចថាមិនស្លូវធ្លាប់អីដូចគេ ចេះញ័រ ។

ឈុនលី ៖ ម៉េច?

យឿន ៖ គេថាមេសុំបាញ់រថក្រោះ ដល់បាញ់ទៅកាណុងសឹងដល់ហើយ ចុះកាណុងគាំភ្លើងធំ រថក្រោះមិនមែនខ្ទីណា៥-៦ម៉ែត្រ ។ ដល់នេះ ហើយចាន់គេនឹកឃើញថារថក្រោះនឹងវាខូចគេ វាអត់បញ្ចេះ ហើយអាប្អូននឹងវាដឹតច្រវ៉ាក់ពោក១ ទៅមកនិយាយគ្នាទៅបានដឹងអី! ។

ឈុនលី ៖ ចឹងកាលនឹងអត់ស្គាល់គ្នា?

យឿន ៖ អឺ! ម៉េចដឹង ម៉េចស្គាល់ ។

ឈុនលី ៖ ហើយម៉េចទៀតទៅ ដុតច្រវ៉ាក់?

យឿន ៖ ដល់ដឹតច្រវ៉ាក់ទៅ នេះក៏ដកថយវិញទៅ ឯងនោះក៏គេអត់ឃើញយើងដែរ តែបើគេមើលនៅក្នុងរថក្រោះ គេមើលរថក្រោះអាចឃើញ គេចុះមកគត ។ ដល់ពេលមកសុខសាន្តទៅត្រូវគ្នាបានគេមក រកនឹកបានចាប់ផ្ដើមនិយាយចុះនិយាយឡើង ខ្ញុំសួរថាចុះឯងដែលមកសមរភូមិកើតអ៊ីងម៉ុងហ៉ឺ? ថាមកតើ ។ ហើយចុះមានរថក្រោះមួយខូចដាច់ច្រវ៉ាក់ទេ? ហ្នឹងហើយខ្ញុំ ចុះមានមេនៅនឹងអត់ ថាមានកងពលម្នាក់នៅនឹង ។ ហើយចុះមាននារីអត់ស្រី១? មាន ស្រីគេនៅក្រោយទូលគ្រាប់ ។ ចុះព្ទសួរមាត់ចេកចាច១ ។

ឈុនលី ៖ ចឹងពូចេះសួរទៅអត់ដឹងថាគាត់ដែរនឹង?

យឿន ៖ អត់ ។

ឈុនលី ៖ ដល់ពេលសួរទៅបានដឹង?

យឿន ៖ ហ្នឹងហើយទាល់តែសួរទៅបានឆ្លើយ ទាល់វាវាយរាប់មកបានដឹងថាប៉ុស បើសិនណារថក្រោះនៅបញ្ចេះឯងត្រូវខ្ទីដែរនឹង ។

ឈុនលី ៖ បងប្អូនឯង?

យឿន ៖ អឺ! នេះគឺព្រោះបងព្រោះតែមើលប្អូនឯងវាអត់ស្គាល់ទេ វាធំជាង ។

ឈុនលី ៖ មករកឆ្នាំណា?

យឿន ៖ ទេ! មករកឆ្នាំណាទេ កាលនឹងមកឆ្នាំត្រូវគ្នា ។

ឈុនលី ៖ ត្រូវគ្នាឆ្នាំប៉ុន្មាន ៩០ប៉ុន្មាន?

យឿន ៖ ទេ! ភ្លេចបាត់ហើយ៩០ប៉ុន្មានទេ ។

ឈុនលី ៖ ៩៦ ៩៧?

យឿន ៖ ៩៣ហី ។

ឈុនលី ៖ ពេលសមាហរណកម្ម?

យឿន ៖ ហ្នឹង ។

ឈុនលី ៖ ៩៦ ហើយ៩៧?

យឿន ៖ ហ៎! បែបខ្វង់ប៉ុននឹង ។

ឈុនលី ៖ ពេលនឹងសម្ដេចមក សម្ដេចហ៊ុន សែនមក?

យឿន ៖ ហ្នឹងហើយ កាលសម្ដេចហ៊ុន សែនមក ខ្ញុំអស់កូនមួយ ។

ឈុនលី ៖ ចុះម៉េច?

យឿន ៖ ចុះឪពុកគេហៅប្រមូលទៅទទួលហ៊ុន សែននៅវត្តនេះសាលារៀននេះ ហើយខ្ញុំនេះទៅខ្ញុំ បើកអាវុធឲ្យម៉ាដើម ហើយស្មៀកពាក់ឯកសណ្ឋានទៅឈរតំរង់ ហើយខ្មែរគេនេះគេឲ្យ ចែកប័ណ្ណ ។

ឈុនលី ៖ ប័ណ្ណអីគេ?

យឿន ៖ ប័ណ្ណបើករបប កាលនឹងមានអង្ករ មានសារុង មាន ។

ឈុនលី ៖ មានត្រីខ?

យឿន ៖ មានត្រីខ ។

ឈុនលី ៖ មី?

យឿន ៖ មី ហើយនឹងចបទៅមកៗអង្ករម៉ាគ្រាប់ក៏អត់បាន មកកូននេះអស់ជីវិតទៀត ។

ឈុនលី ៖ ម៉េចចឹង កូននឹងប៉ុនណា?

យឿន ៖ កូនម៉ាខួប ។

ឈុនលី ៖ ម៉េចចឹង?

យឿន ៖ ឲ្យអាបងៗនៅ កាលនឹងអានេះអត់ទាន់កើតទេ ។

ឈុនលី ៖ កូនហ្នឹងកូនបង?

យឿន ៖ អត់ទេ ប្អូន អាបង២នាក់ទៅណាបាត់ហើយទេ នោះទើបលើកក្រោយ ។

ឈុនលី ៖ ម៉េចទៅពូ?

យឿន ៖ មិនដឹង ខ្យល់ ខ្ញុំនឹងទៅតំរង់ផ្លូវគេថាទៅអបអរសាទនឹង ទៅឈរហាលថ្ងៃឡើងក្ដៅចេះ ហើយប្រពន្ធនឹងគេឲ្យប័ណ្ណនឹងទៅចាំបើកៗរបបនឹង ទៅមានអីម៉ោង១ជាងហើយ វាក្ដៅ ពេក សុំៗមេនឹងថាខ្ញុំនៅគ្រប់គ្រងមិនបានទេ គេឲ្យមកៗអត់មានដើរឆ្វេងឆ្វាចពីមុខទេ ដើរ មកសសៀលៗដើរចូលនេះចូលប្រឡោះៗបានមកក្រៅបានចេញបាន ។ ដល់មកដល់ផ្ទះកូន នេះវាទន់ៗចាប់ផ្ដើមឲ្យម្នាក់រត់ទៅហៅម៉ែៗ ទុកបុងនឹងទុកឲ្យស្រួលសម្រាប់ទុកបើករបបនឹង ដល់ពេលម៉ែវាមកចាប់ផ្ដើមយកទៅពេទ្យៗ អាប្អូននោះឱុបទៅប្អូន.......។ ដល់ឱុបទៅដល់ ពេទ្យនោះក៏អត់មានបានពិនិត្យបានអីទៅដល់ឲ្យថ្នាំលេបថ្នាំអី គ្រាន់ចាក់ៗមិនទាន់អស់ថ្នាំផង

ដើង ខ្ញុំងដើងនេះកូនឡើងកោងវីង អាមួយស្ទាបអាអ្នកឌុបទៅអាប្អូន អើបងអត់ដង្ហើម ហើយនឹង ឡើងរឹង ។ ដល់ពេលនេះរកកន្លែងគិតគូនេះ រួចហើយសុំរបបពីគេ គេថាអត់ ។

ឈុនលី ៖ ពូចឹងកាលនឹងមានបណ្ណរបបអីចឹង បាននយ័ថាខ្ញុំមុនសមាហារណកម្មនឹង យើងបើករបប រហូត?

យឿន ៖ ទេ! អានឹងរបបកាលពីសម័យខ្មែរក្រហមបើករហូតនឹង ។

ឈុនលី ៖ រហូតដល់សមាហារណកម្ម?

យឿន ៖ ហ្នឹងហើយ សមាហារណកម្មក៏នៅតែបើក ។

ឈុនលី ៖ បើគិតទៅពូដូចថាចេញពីទឹកដីថៃមកនៅនេះរហូតអីចឹង ពីឆ្នាំណា?

យឿន ៖ ទេ! អាទឹកដីថៃនឹងចូលបានម៉ាខ្សែតទេ ។

ឈុនលី ៖ ចា៎! ប៉ុន្តែដល់ពេលយើងឈប់អាពេលដែលយើងមកនៅបោះទីតាំងនៅនឹងវិញ?

យឿន ៖ មកនៅនេះ?

ឈុនលី ៖ ចា៎!

យឿន ៖ ហ៊ឺ! មិនដឹងឆ្នាំប៉ុន្មាន ។

ឈុនលី ៖ ចូលខ្ទង់៩០ឥឡូវ?

យឿន ៖ ហ៊ឺ! មិនទាន់ទេហី ។

ឈុនលី ៖ ហើយក៏នៅ៨០ដាង?

យឿន ៖ អឺ! មិនដឹងប៉ុន្មាន អត់ចាំ ។

ឈុនលី ៖ ហើយដល់មកនៅភូមចឹង មិនសុទ្ធតែមីនមិនចឹង ពិបាកទេកាលរស់នៅ?

យឿន ៖ រឿងពិបាកៗហើយ តែមីនខ្លះ ដាច់ជើងទាំងពីរ នេះដាច់នៅភូមិមាត់អូរនេះ អានឹងគេរាវ ធ្វើដំរកចឹង ។

ឈុនលី ៖ ចុះចំពោះពូផ្ទាល រាវដែរ?

យឿន ៖ ទេ! ខ្ញុំរាវតែពេលឃើញនឹងឯង តែពេលចូកម៉ាប៉ែលៗទេ ។

ឈុនលី ៖ ចុះពេលមកនៅនឹងវិញ មានព្រៃច្រើនទៀតអត់ ព្រោះតំបន់នេះនៅព្រៃចឹង?

យឿន ៖ ទេ កាលពីមុននោះអត់ទាន់មានមកនៅទេ ដែលយើងដែលគេជំរុញមកចចារ ។

ឈុនលី ៖ ពេលរត់ពីភ្នំពេញមក?

យឿន ៖ ហ៊ឺ! ពីភ្នំពេញមិនទាន់ដល់នេះទេ ហ្នឹងហើយតាំងពីរត់មកនេះទៅស្នឹកន្លែងប៉ៃលិននេះ រត់ ទៅម៉ារយៈទៅអើយនិយាយពី ។

ឈុនលី ៖ ពិបាកណាស់ធ្វើម៉េចទៅ?

យឿន ៖ វេទនាចុះគេយកទៅដាក់ចន្លោះភ្នំ ដែលឈើ ។

ឈុនលី ៖ ចាញ់?

យឿន ៖ ហ្នឹងហើយ ដែល.........និយាយពីនៅច្រកភ្នំជុំវិញ គេយកទៅដាក់នឹង ។

ឈុនលី ៖ យូរប៉ុហ្មាន នៅនឹង?

យឿន ៖ នៅជិតម៉ាឆ្នាំ បានម្នាក់ៗឃើញឈឺច្រើនពេក អានេះទាមទារ អានេះដោយសារគេអ្នកធ្វើធំផងទេ គេអ្នកកងពលកូនគេស្លាប់ ។ ទាល់ស្លាប់បានគេជិនះមកៗ ១ឃើញមក ២ឃើញមកៗតាមគ្នា ។

ឈុនលី ៖ មកៗទាំងអស់?

យឿន ៖ អឺ!

ឈុនលី ៖ ចុះដល់ពេលសុទ្ធតែព្រៃចឹង ចង់សួរពូថាពេលពូចេញពីដីថៃមកអីចឹង សុទ្ធតែព្រៃដែល?

យឿន ៖ ហ្នឹងហើយ ព្រៃនៅព្រៃ តែយើងមកយើងជិនះយើងត្រូវ មុនដំបូងចាប់បានតែកន្ទែលចងអង្រឹងទេ ។

ឈុនលី ៖ ដេកលើអង្រឹងនឹងទៅ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចុះយើងមានកូនមានអី?

យឿន ៖ ចុះកាលនឹងយើងមានកូនប៉ុន្មាន តែមួយនោះ កាលនោះ ។

ឈុនលី ៖ កូននឹងកើតនៅណា?

យឿន ៖ កើត កូននឹងកើតនៅដីថៃ ។

ឈុនលី ៖ ហើយមានការលំបាកអីទៀតអត់ មានសត្វព្រៃអីអត់ បើសុទ្ធតែព្រៃ?

យឿន ៖ យី! អារឿងសត្វវាតែងតែមានហើយ មានពស់ មាន ។

ឈុនលី ៖ ខ្លាមានអត់?

យឿន ៖ ទេ! ខ្លាដូចជាមិនដែលប្រទះដែរ តែបងៗជួបនឹងដីនេះ ។

ឈុនលី ៖ កូនមែនពូ?

យឿន ៖ កូន ។

ឈុនលី ៖ កូនប៉ុន្មាននាក់?

យឿន ៖ កូន៥នាក់ ។

ឈុនលី ៖ ចុះបន្ទាប់ពីមកពីនឹងវិញ ពិបាកអីទៀតទៅ?

យឿន ៖ អារឿងការលំបាកវាចេះតែមានបន្តបន្ទាប់ មានការលំបាកជីវភាព រឿងទឹកៗមិនមែនងាយទេ ទឹកដងម៉ាម៉ោង ។

ឈុនលី ៖ នៅណា?

យឿន ៖ មាត់អូរៗព្រំដែន ហើយខ្ញុំមិនសូវបាននៅជាមួយគ្រួសារទេ តែនេះនឹងគេជំរុញទៅនោះហើយ ដូចថាកងដឹកជញ្ជូន ។

ឈុនលី ៖ ចឹងពូមកវិញនៅកងដឹកជញ្ជូនរហូត?

យឿន ៖ហ្នឹងហើយ ។

ឈុនលី ៖ ចុះប្រពន្ធពូធ្វើអី?

យឿន ៖ ប្រពន្ធនៅតែផ្ទះនឹង ។

ឈុនលី ៖ ពីមុនមកគាត់នៅធ្វើអី?

យឿន ៖ ទេ! ពីមុនមកកាលពីមុនពេទ្យ ធ្វើពេទ្យ តែពេទ្យដូចថាអាបាយជ្រូកក៏ពេទ្យនឹង តែគ្នាអត់ចេះអក្សរ ហើយគេចេះតែហៅទៅ ។

ឈុនលី ៖ ហើយដូចពូថាការរស់នៅនឹងវាលំបាកម៉េចខ្លះ អត់ទឹក?

យឿន ៖ អារឿងទឹកនឹង ទើបឥឡូវទេ មានតក់ៗទៅ ។

ឈុនលី ៖ ហើយអូរប្រើគ្រប់គ្នាដែរ?

យឿន ៖ ចុះអូរព្រំដែន អូរ... កាលនោះមិនមែន ។

ឈុនលី ៖ ទៅដងឆ្ងាយៗ?

យឿន ៖ ហ្នឹងហើយ ម៉ាម៉ោងមិនបានវិញ មិនមែនរែកទេ កាដុងយើង២៥លីត្រទូលមកហើយ ។

ឈុនលី ៖ ពូអ្នកទូលខ្លួនឯង?

យឿន ៖ គ្រួសារ ។

ឈុនលី ៖ ហើយពូកន្លែងទៅដឹកជញ្ជូនស្បៀងទៅ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ចឹងពេលនឹងមានច្បាំងគ្នាទៀត?

យឿន ៖ មាន ។

ឈុនលី ៖ ជាមួយខាងណា?

យឿន ៖ ខាងវៀតណាមនឹង ។

ឈុនលី ៖ ឆ្នាំពេលមកពីថៃ៩០ជាង ៨៩ ៩០?

យឿន ៖ អឺ! ទេមិនដឹងជាឆ្នាំប៉ុន្មានកាលនឹងខ្ញុំអត់ចាំ ។

ឈុនលី ៖ ហើយដូចហូបចុកអីគ្រប់គ្រាន់អត់?

យឿន ៖ ទេ! ដល់មកនេះយើងហូបរបបបើក ។

ឈុនលី ៖ បើករបបរហូត?

យឿន ៖ ហ្នឹងហើយ អង្ករម៉ោអាទិត្យបើកម្ដង កន្ទះខែបើកម្ដង ហើយប៊ីចេង ម្សៅអីបើក ទឹកត្រីបើក

ឈុនលី ៖ ចុះមានពេលណាខ្វះខាត?

យឿន ៖ ទេ! អាពេលដែលនិយាយរឿងខ្វះខាតនឹង កាលពីលើមុនអត់ហ៊ានរត់លួន ខ្ញុំចេញពីភ្នំពេញមករហូត ។

ឈុនលី ៖ តែដល់ពេលមកដល់ មកនៅនេះហើយ គឺការហូបចុកគ្រប់គ្រាន់ទាំងអស់?

យឿន ៖ ទេ! វាមិនគ្រប់ទេ វាខ្វះខាតចុះរបស់បើកដូចជឹកស្រាប់ហើយ ជួនកាល ។

ឈុនលី ៖ បើកយឺត?

យឿន ៖ ហ្នឹងហើយ ជួនកាលយើងខ្វះទៅៗសុំទៅ ឯងនោះគេថាមិនទាន់ដឹកមកចេះចុះ គេមិនដូចយើង ។

ឈុនលី ៖ ចុះពូដល់ពេលមកនៅណឹងចឹងមិនអ្នកចេញពីថៃមកគ្នាច្រើន មែនអត់?

យឿន ៖ ទេ! មិនជាច្រើនទេ យើងចេញមកបន្ដៗ ។

ឈុនលី ៖ ពូចេញមកមុនក្រោយ មុនគេហើយក្រោយគេ?

យឿន ៖ ទេ! គេមានគេចេញមកមុនទៀត មានតែគេទេ មានតែមេដែលគេចេញមកមុន ក្រុមគ្រួសារមេៗ ។

ឈុនលី ៖ មេៗរត់ទៅនឹងដែរ?

យឿន ៖ អឺ! ទៅទាំងអស់ នេះអត់មាន ។

ឈុនលី ៖ មេដូចលោកសុខ ភាពអីនឹង ទៅនឹងដែរ?

យឿន ៖ ទេ! សុខ ភាពដុះគេច្រើន នៅថៃក៏មានៗ តែប្រពន្ធកូន តែទៅភ័យគេសាលាគេមាន ឲ្យតែយើងតូចតាច ។

ឈុនលី ៖ ចុះដល់ពេលនៅចេះចឹងពិបាក ដូចជួបសង្គ្រាមពូនឹកផ្ទះ នឹកស្រុកកំណើត?

យឿន ៖ ទេ! ទាល់ចឹងលែងសួរនឹកហើយ វាបែករាប់ឆ្នាំហើយ នឹកឃើញថាគេម៉េចឯងម៉េច ។

ឈុនលី ៖ ចឹងសភាពការណ៍នៅនេះ ដូចថាពូថាគ្រាប់បាញ់គ្នា?

យឿន ៖ អឺ! ថាកន្លែងនេះកន្លែងសមរភូមិហើយ កើតបានកូនខ្មែរយើង នៅបីអន្ទុយបណ្ដើរ ។ ជួនកាលគេថាហ៎! ឥឡូវយួនមកដល់នេះហើយ ឥឡូវឲ្យយើងដកឃ្លាទៅនឹងផ្ទះអឹមាត់អូរ បបួលគ្នាទៅនឹងទាំងអស់គ្នា ដ្កុកកកុញគ្នា បើសិនគ្រាប់ធ្លោងដាក់ម៉ាគ្រាប់ដឹងអស់ប៉ុន្មានឡើង

នែន ។ ហើយចូលទៅថៃ១ដាក់យើងអត់ទាន់មានច្បាប់ យើងខាងអត់ទាន់មានការទាក់ទង
គ្នាបានឲ្យចូល ។

ឈុនលី ៖ ហើយចឹងមកដល់ម៉ាឡៃចឹង នាំគ្នាដោះមីនដោះអីរស់នៅធម្មតា?

យឿន ៖ បាទ!

ឈុនលី ៖ ចុះដល់ពេលគេសមាហរណកម្ម ដល់ពេលក្រោយពេលខ្មែរក្រហមដួលចំខ្លួននឹង អានឹងពួរស់នៅរបៀបម៉េច?

យឿន ៖ ទេ! កាលនឹងរស់នៅនឹងឯង តែដល់ពេលកាលនឹងដូចថាត្រូវរួវគ្នា យើងគ្រាន់គេប្រជុំប្រាប់ថាឥឡូវសុខសាន្ត រួបរួមគ្នាប្របាច់ចូលគ្នា ។ ចឹងបានមានគំនិតម្នាក់ៗវាអររំភើបទៅ នឹកឃើញថាអានេះខ្មែរសម្លាប់ខ្មែរគ្នាឯង ។

ឈុនលី ៖ ហើយម៉េចទៀតទៅ?

យឿន ៖ មានអីគេគ្រាន់ប្រជុំប្រាប់ ឥឡូវថាកំណត់ ។

ឈុនលី ៖ ចុះមានចែករបបចែកអីទៀតអត់?

យឿន ៖ ចែក នៅចែក ។

ឈុនលី ៖ ចែកដល់ពេលណា?

យឿន ៖ ចែកដល់ពេលយើងចប់ ដូចថាប្របាច់ចូលគ្នាមែនទែន នេះលែង១ហើយរំលាយខ្លួន ។

ឈុនលី ៖ ខ្វង់ឆ្នាំណា ពេលនឹង?

យឿន ៖ វាអត់ចាំ ។

ឈុនលី ៖ គេមានឃ្លាំងគេមួយនៅកន្លែងណា?

យឿន ៖ ឃ្លាំងគេនៅកន្លែងឥឡូវគេរូសយូរហើយ ចុះបើចូលគ្នាអស់ហើយ នៅខាងជិតកន្លែងគយ ។

ឈុនលី ៖ កន្លែងគយ?

យឿន ៖ គយ មិនមែនអាមាត់អូរនេះ កន្លែងផ្ទះលេខមួយនេះ ជិតគ្នានឹង នៅកន្លែងឃ្លាំងនឹងអាកន្លែងគយកន្លែងមាត់អូរនឹងអានឹងកន្លែងច្រកគេយាម ជិតគ្នានឹងឯង ។

ឈុនលី ៖ ចឹងដល់ពេលយើងត្រូវរួវគ្នាមិនលែងមានសង្គ្រាម១ចឹង ដូចពូក៏លែងទៅកន្លែងស្បៀងគេដែលទៅដឹកជញ្ជូនអីដែរ?

យឿន ៖ អឺ!

ឈុនលី ៖ ចឹងនៅផ្ទះ?

យឿន ៖ នៅផ្ទះ ។

ឈុនលី ៖ ធ្វើអី?

យឿន ៖ ក្រោយឡើងគេប្រាប់ចូលគ្នាឲ្យទៅនៅបន្ទាយនោះ ខ្ញុំ ។

ឈុនលី ៖ ពូចូលធ្វើ?

យឿន ៖ ទាហានៗខាងនៅលោក សូ ចាន់ហេង នៅព្រះនេត្រព្រះ តែឥឡូវនឹងខ្ញុំឈប់ហើយ ដាច់ឯងម៉ង ។

ឈុនលី ៖ ឈប់ពីឆ្នាំណា ប៉ុន្មានឆ្នាំ?

យឿន ៖ ឈប់២ឆ្នាំ ៣ឆ្នាំហើយដឹង ។

ឈុនលី ៖ ចឹងតាំងពី២០០៦?

យឿន ៖ មិនដឹងប៉ុន្មានឆ្នាំទេ ។

ឈុនលី ៖ ២០០៦ ២០១០?

យឿន ៖ ចុះបើមេធ្វើបាបពេក ។

ឈុនលី ៖ ធ្វើបាបម៉េច?

យឿន ៖ អារឿងប្រាក់ខែរឿងអីនឹង ចុះបើខ្ញុំវាឈឺទៅ ឲ្យកូនទៅបើកគេស្តីឲ្យកូនៗ លែងហ៊ានទៅបើក ឲ្យម៉ែទៅបើកស្តីឲ្យម៉ែ......ស្អីក៏អត់ៗគិតថាខំយូរហើយ...........ត្រូវការម៉ោង៣យប់ទៅទាំងយប់ ឈឺទៅទាំងឈឺ បងពេទ្យនេះបងពេទ្យ ។

ឈុនលី ៖ គាត់ធ្វើពេទ្យ?

យឿន ៖ នេះពេទ្យគាត់ព្យាបាលពួកខ្ញុំ......គេហៅទៅស្ថានណាក៏ទៅអី! គេ......ដល់ទៅបើប្រាក់ខែដូចធ្វើបានគ្នា ។

ឈុនលី ៖ អូ!ចឹងបានន័យថា ពេលនៅនឹងគាត់ធ្វើពេទ្យទាហាន ហើយពូធ្វើទាហាន?

យឿន ៖ បាទ!

ឈុនលី ៖ ដល់ពេលឈប់ៗជាមួយគ្នា?

យឿន ៖ អត់ទេគាត់មានអី មានរបបជាប់រហូតនឹង ហើយដល់ពេលឥឡូវពេទ្យគាត់ដើរព្យាបាលគេតាមភូមិ លែងទាហានលែងអីអស់ហើយ គាត់ចូលខាងផ្តាច់ខ្លួន ។

ឈុនលី ៖ និវត្តន៍?

យឿន ៖ អឺ!ហ្នឹងហើយគេមានរបបជាប់ ខ្ញុំគ្មានស្អី វាខឹងខ្លាំងពេក ។

ឈុនលី ៖ ចុះពូគេមានចែកដីចែកអីឲ្យទេ ពេលនឹងពេលដែលផ្តាច់ខ្លួនហើយ?

យឿន ៖ គេអត់ៗមានចែកឲ្យ តែអាដីនេះសុទ្ធតែដីចាប់រាវខ្លួនឯង ។

ឈុនលី ៖ និយាយទៅគិតទៅផ្ទះនេះ ពូមកនៅពេលណា ឆ្នាំណា ពេលណា?

យឿន ៖ មុន ។

ឈុនលី ៖ មុនទៅជំរំ?

យឿន ៖ អត់ទេ ទៅជំរំស្អី ទៅជំរំមិនដែលស្គាល់នេះផង ។

ឈុនលី ៖ ចឹងទើបមកវិញ មកដល់ជំរំហើយមកនៅនេះ?

យឿន ៖ បាទ!

ឈុនលី ៖ ជំរំនឹងគេហៅជំរំស្អីគេ?

យឿន ៖ ជំរំនឹង ជំរំថារដ្ឋគេទិញដីៗថៃ គេហៅខ-៨៥ ។

ឈុនលី ៖ បើគិតទៅគ្រាន់តែរយៈពេលចេញចូលនឹងប៉ុន្មានឆ្នាំ គ្រាន់ពេលយើងទៅនៅដីថៃ ហើយយើងចេញចូលមកដល់មក?

យឿន ៖ ទេ! កាលនឹងនៅប៉ុន្មាន នៅម៉ាឆ្នាំ ។

ឈុនលី ៖ អត់ចាំ?

យឿន ៖ អត់ចាំ ទេ!ខ្ញុំអាចបើបងគាត់ចាំ ។

ឈុនលី ៖ តែដឹងថាមកជាមួយគាត់?

យឿន ៖ នៅជាមួយគ្នានឹង ។

ឈុនលី ៖ ចុះគាត់ពីដើមគាត់ធ្វើអីគេ?

យឿន ៖ ទេ! កាលនឹងគាត់អត់មានធ្វើស្អីទេ កាលនឹងភូមិដឹង ក្មេចបាត់ទៅ ។

ឈុនលី ៖ ចុះដូចស្រុកម៉ាឡៃនេះ ពីដំបូងមិនសុទ្ធតែព្រៃ ហើយចឹងម៉េចបានគេបង្កើតជាស្រុក?

យឿន ៖ ចុះបើវាលអស់ហើយ ។

ឈុនលី ៖ ឆ្នាំណាគេបង្កើតជាស្រុកមែនទែន?

យឿន ៖ ដឹងឆ្នាំណាទេ ខ្ញុំទៅសួររឿងឆ្នាំអត់ ។

ឈុនលី ៖ ពេលណាផ្ដាច់ខ្លួនហើយនៅ?

យឿន ៖ ទេ! កាលស្រុកម៉ាឡៃនេះមិនទាន់ផ្ដាច់ទេ កាលនោះមនុស្សនៅពេញអស់ហើយ តែពេញវាមិនដល់ដូចឥឡូវៗ ភាគច្រើនមកពីខាងក្នុងៗមកៗរកស៊ី គេអ្នកមករកស៊ី នេះសុទ្ធតែអ្នកអត់ដែលស្គាល់ដែរ ។

ឈុនលី ៖ តែពួកគាត់មកពេលក្រោយផ្ដាច់ខ្លួន?

យឿន ៖ ក្រោយៗផ្ដាច់ខ្លួន ។

ឈុនលី ៖ ចុះពូដល់ពេលមក ដល់ពេលផ្ដាច់ខ្លួនហើយចឹងពូនៅធ្វើទ័ព មីងគាត់នៅផ្ទះ ពេលនឹងរបបនៅតែមានដោយសារពូធ្វើទ័ពនឹង?

យឿន ៖ បាទ! មាន ។

ឈុនលី ៖ តែគ្រប់គ្រាន់អត់?

យឿន ៖ ទេ! បើមានរបស់បើកវាមានខ្វះដែរនឹង តែអានេះបើកគេបើកម៉ាចប់ តាំងពីទឹកត្រី ប្រហុក អំបិល ប៊ីចេង អង្ករ ស្ករ ទឹកដោះគោអី គេបើក ។

ឈុនលី ៖ ហើយពូឥឡូវនឹងដែរទៅលេងស្រុកកំណើតដែរ?

យឿន ៖ ទៅ! តែគ្រាន់ខានទៅប៉ុន្មានឆ្នាំ ហើយឪពុកស្លាប់ក៏អត់ទាន់ដង្ហើម ថាម្ដាយនោះអត់ដែលស្គាល់ ។

ឈុនលី ៖ ចុះពេលដែលគេផ្ដាច់ខ្លួនហើយចឹង មានបងប្អូនពូមករកពូនៅនេះអត់?

យឿន ៖ ទេ! មានៗជាមួយនៅភូមិ តែបងប្អូនអត់ តែមកៗគេមករកកូនគេទាល់មកឃើញ ដើរមកដល់នេះ ខ្ញុំក្រលេកទៅឃើញធ្លាប់ស្គាល់ ហើយគាត់អត់ចាំ ។

ឈុនលី ៖ ពេលផ្ដាច់ខ្លួនហើយ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ពេលមកដល់ឃើញពូចឹង ថាម៉េច?

យឿន ៖ គាត់អត់ស្គាល់ខ្ញុំទេ តែខ្ញុំតើឃើញគាត់ដើរចូលនេះ តែអត់មានផ្លូវទេ សុទ្ធតែភក់ មកខ្ញុំសួរចំអ្នកណាដូចតាឆៅ អឺ!បានស្គាល់ ។

ឈុនលី ៖ គាត់អ្នកស្រុកកណ្ដាល?

យឿន ៖ បាទ! គាត់មកពីផ្ទះមកពីស្រុក មករកកូនគាត់ ហើយកូនគាត់នៅជាមួយគ្នា តែគេនៅ ។

ឈុនលី ៖ កូនស្រី កូនប្រុស?

យឿន ៖ ប្រុស ។

ឈុនលី ៖ កូនគាត់ឈ្មោះអីគេ?

យឿន ៖ ឆេង ។

ឈុនលី ៖ មកជាមួយពូដែរ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ រត់ជាមួយពូដែរ?

យឿន ៖ ហ្នឹងហើយ កាលគេត្រូវមីន ខ្មែរយើងបង្ហាត់និយាយ ហើយថៃ ខ្វាក់ភ្នែកៗផងត្រូវបំពង់កនេះ ហើយឥឡូវនិយាយ ។

ឈុនលី ៖ និយាយអត់ចេញ?

យឿន ៖ អឺ! កាលនោះនិយាយមានកើតអី តែឥឡូវម៉ែវាចេះបង្ហាត់និយាយឥឡូវនិយាយបានស្ទានអត់ចេះនិយាយណា ។

ឈុនលី ៖ ហើយគាត់មានគ្រួសារដែរចឹង?

យឿន ៖ ឥឡូវមានហើយ កូនប៉ុន្មាន គេទៅនៅជរំតាង៉ុកនោះ ។

ឈុនលី ៖ និយាយបានដូចគ្នា ដូចគេដូចឯង?

យឿន ៖ អឺ! តែឥឡូវគេនៅនោះ នៅស្រុកនោះ ។

ឈុនលី ៖ ហើយដល់ពេលចុះពូទៅលេងស្រុកវិញនៅពេលណា?

យឿន ៖ ខ្ញុំទៅណា ទៅរាល់ដង ។

ឈុនលី ៖ ទៅស្អាង ទៅស្រុកកណ្តាលស្ទឹង ទៅលេងស្រុកកំណើត?

យឿន ៖ ដូចកាលនឹងខ្ញុំទៅឆ្នាំប៉ុន្មាន ទៅកាលនោះឪពុកកាលនៅរស់នោះ គាត់ប័ង្សុកូលអស់ហើយ ។

ឈុនលី ៖ ចុះគាត់ស្មានតែពូបាត់ទៅចឹង?

យឿន ៖ ហ្នឹងហើយ អត់ៗ រកគ្រូគេមើល៣ គ្រូមួយថាសូន្យ គ្រូ២ទៀតថាសូន្យ ថាលោកគ្រូលើកទី៣ថាអត់សូន្យទេ នៅទិសខាងលិច ។

ឈុនលី ៖ ត្រូវ?

យឿន ៖ ត្រូវ ថាតិចទៀតអាចដឹងដំណឹងហើយ ។

ឈុនលី ៖ ចឹងគាត់នោះចាំតែដូវរហូត?

យឿន ៖ តែទៅប័ង្សុកូលនៅស្រុកភូមិថា អឺ!ឪឯងប័ង្សុកូលឲ្យ៣ដងហើយ ។ ហើយទៅនឹងនៅជួបពូគ្រាន់តែពូនៅភូមិជាមួយគេទេ គ្រាន់តែឃើញចុះពីឡាន គេគ្រាន់ឃើញគេគ្រាន់ថាដែរ ចុះពីណាគេដូចយឿនៗ ខ្ញុំផាកទៅ...។

ឈុនលី ៖ ហើយទៅដល់ចឹងអ្នកស្រុកអ្នកភូមិគេ?

យឿន ៖ អឺ! មកសួរនាំ ។

ឈុនលី ៖ ហើយគេដឹងថាពូនៅធ្វើខ្មែរក្រហម?

យឿន ៖ បាទ!

ឈុនលី ៖ ហើយចឹងអាចថាមានអ្នកស្រុកអ្នកភូមិគេខឹងអីជាមួយខ្មែរក្រហម?

យឿន ៖ ទេ! ដូចមិនមានពួសួរនិយាយអី គ្រាន់ថាសួរនាំជីវភាព ហើយចុះពួសួរថាខាងពួកព្រៃនឹងស៊ីស្លឹកឈើ ស៊ីកន្ទឹង ស៊ីករមៀត ចុះម៉េចកូនឯងសាច់ស្អាតម៉េច? ថាអឺ!ចាំតែស៊ីកឈើទៅនៅព្រៃសំសាច់ហូបជាងអ្នកស្រុកទៀត ។

ឈុនលី ៖ សាច់សត្វព្រៃ?

យឿន ៖ ហ្នឹង ឈ្លូស ប្រើស អន្សោម ក្តាន់អីចឹង ជ្រូកព្រៃ អន្សោម ។

ឈុនលី ៖ ចាប់បានចែកគ្នា?

យឿន ៖ ចុះមីននោះ គេដាក់ទំនេរដាក់មីនៗព័ទ្ធជុំវិញ ការពារ ។

ឈុនលី ៖ ដល់ពេលចូលមកផ្ទះ?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ហើយមិនបែកសាច់ពេញនឹង?

យឿន ៖ ទេ! អត់អី ។

ឈុនលី ៖ ខស្សរាហ៍បានហូបដែរ?

យឿន ៖ អឺ! កាលនឹងគេថាខ្មែរក្រហម ហើយប៉ាវ៉ាអត់ត្រូវគ្នា តែក្រោយឡើងប៉ាវ៉ាបានមកគេចែក គ្នា ស៊ីដឹកជុំគ្នា ហើយអាទាហានខ្មែរក៏នេះ ។

ឈុនលី ៖ អានឹងពេលណា?

យឿន ៖ ពេលដែលយើង កំពុងច្បាំងគ្នានឹងឯង តែវាមាន ។

ឈុនលី ៖ គេត្រូវគ្នា?

យឿន ៖ ហ្នឹងវាមានត្រូវគ្នា មកខាងនោះខាងក្នុងក៏មកៗ មកព្រៃនឹងក៏ចាប់ផ្ដើមបានសាច់ ចុះសាច់ ផ្ទះមីនរាល់យប់ចែកចាយហូបស៊ីដឹកជុំគ្នានឹង ។

ឈុនលី ៖ មានស្រាអត់?

យឿន ៖ អឺ! ខ្វះអីស្រាក្នុង ។

ឈុនលី ៖ ខាងខ្មែរក្រហមយើងនេះមានស្រាដែរ?

យឿន ៖ អឺ! មានដូចតែគ្នា តែវាគ្រាន់វាមិនដូចខាងនោះៗគេមាន គេអូទាក់ទងគ្នា ឯងយកទឹកមក ពីនោះមកវើយ! យកមកសុទ្ធតែមេៗមានកូន ។

ឈុនលី ៖ ពូអត់ដែលស្គាល់គេ?

យឿន ៖ អត់ទេ អត់ដែលស្គាល់ទេ ។

ឈុនលី ៖ ហើយដល់ពេលក្រោយទៅខស្សរាហ៍ទៅលេងដែរ?

យឿន ៖ បានឆ្នាំ...ប៉ុន្មានគេស្ដមកថាឲ្យទៅការក្ដួយ ជិតវត្តស្ទែង ។

ឈុនលី ៖ ជិតវត្តអីគេ?

យឿន ៖ វត្តស្ទែង ។

ឈុនលី ៖ វត្តស្ទែង?

យឿន ៖ ស្គាល់?

ឈុនលី ៖ អត់ស្គាល់! មានក្រុមការងាររខ្ញុំម្នាក់គាត់នៅខេត្តកណ្ដាល ស្រុកកណ្ដាលស្ទឹង ។

យឿន ៖ ខ្ញុំនៅជិតទន្លេបាទី ។

ឈុនលី ៖ ជាយទៅខាងនោះវិញ?

យឿន ៖ តែវាថាជិតយើងជិះកង់ទៅរក ថាពីដើមទៅរកត្រីរកអីទន្លេបាទី តែចុះទៅដល់ផ្សារដើមគ្រ នឹងចុះដើរទៅម៉ាគីឡូកន្លះដល់ៗ តែឥឡូវបងនៅនេះវិញ នៅវត្តស្វែងវិញ នៅជិតអាវត្តព្រៃស កាលពីមុនគេហៅគុកព្រៃស ។

ឈុនលី ៖ ចុះពូដល់ពេលគេត្រូវរំរូវគ្នាអីចឹង ចាប់ផ្ដើមមានអ្នកចំណូលថ្មីមកនៅក្នុងស្រុកនឹងហើយ?

យឿន ៖ បាទ! ភាគច្រើនណាស់ នៅផ្សារនេះសុទ្ធតែអ្នកថ្មី ។

ឈុនលី ៖ មកចឹងដូចគេភ័យខ្លាចរឿងខ្មែរក្រហមអត់?

យឿន ៖ ទេ! បើភ័យខ្លាចគេមិនមក តែមើល គេថាមកខ្មែរក្រហមណា សុទ្ធតែខ្មែរគ្នាឯង ។ មួយគេថាទេ! ខ្មែរក្រហមៗ នឹកមិនខ្មែរក្រហម សុទ្ធតែខ្មែរគ្នាឯង ។

ឈុនលី ៖ ចុះពូដែលពួគេនិយាយថា ដូចដែលពូនិយាយនៅមុខពូថាខ្មែរក្រហមអាក្រក់មានទេ?

យឿន ៖ ពួៗគេនិយាយ តែភាពដូចខ្ញុំនិយាយវែងឆ្ងាយ ដូចនៅជងអារញ្ញ កាលនឹងនៅវៃគ្នា ទៅប្រជាជនគាត់មក ខ្ញុំចុះទៅដេកវត្តដេកព្រៃអី ។ ទៅដល់គាត់ប្រជាជនគាត់ថា និយាយជាមួយពួកនេះថា យ៉េ! ពួកអាប៉ុលពត ហើយដល់នេះចាប់ផ្ដើមមើលៗកងពល មិនមែនលោកសុខ ភាពទេ លោកនី ស្អីនីនឹង ។

ឈុនលី ៖ ឈ្មោះនី?

យឿន ៖ ហ្នឹងហើយ គាត់សួរ ហើយខ្ញុំក៏សួរទៀតថា ទេ!អ៊ំប៉ុលពតនឹងចំណាស់ណា គាត់ក៏ឆ្លើយគាត់ថាមិនដឹងចំណាស់ណាផង ចុះម៉េចបានក៏ជេរគាត់ ហើយមុខគាត់ម៉េច? មិនដឹងមុខម៉េច ចុះម៉េចបានស្អប់គាត់? គាត់ថាចុះពួគេជេរៗតាមគេ ។ ហ៉ា!ឥឡូវខ្ញុំប្រាប់ថាអ៊ំប៉ុលពតនឹងគាត់ចាស់ហើយ ឥឡូវគាត់ស្លាប់ទៅហើយ គាត់ដើរមិនរួចទេ ហើយគាត់ធ្វើឪពុកអ៊ំឯងបានៗ ចុះខ្ញុំធ្លាប់ឃើញហើយ ។

ឈុនលី ៖ ហើយគាត់ហៅអារ?

យឿន ៖ អឺ! គាត់ជេរ តែដល់សួរគាត់ថាគាត់អត់ស្គាល់ គាត់ជេរតាមគេ មែនទែននឹងខ្ញុំពួគេថាប៉ុលពតសម្លាប់ៗនឹង ។ ខ្ញុំវាមិនដែលអ្នកសម្លាប់នឹងច្រើនអ្នកបំភ្លៃ នឹងតាមខ្ញុំយល់ទេណា តែបើថាខ្ញុំកាលនឹងដូចថានៅភ្នំពេញដូចថាដល់ថ្ងៃៗ១០អីចឹង ១០ថ្ងៃត្រូវមានបន្ថែមមានអីឲ្យអ្នកសហករណ៍នឹងគេហូប ។

ឈុនលី ៖ កាលនឹងពូនៅភ្នំពេញ?

យឿន ៖ នៅក្រសួងបរទេសនឹង តែគេអ្នកធំៗតែដល់ថ្ងៃ១០គេចុះដើរមើលហើយ ។ ដល់ដើរមើលទៅដើរមើលបេះសួរហើយ អ៊ំណាៗនឹង ។ គេប្រាប់នឹងហើយអ៊ំប៉ុលពត អឺ!ចាស់ហើយ ។

ឈុនលី ៖ កាលនឹងចឹងពូបានឃើញគាត់ផ្ទាល់?

យឿន ៖ បាទ!

ឈុនលី ៖ ហើយឃើញអ្នកណាទៀត អ្នកធំៗចឹង?

យឿន ៖ ទេ! ឃើញៗអ៊ីប៉ុលពតនឹង ហើយគានួន ជា អៀង សារី ។

ឈុនលី ៖ អ៊ំខៀវ សំផនអីដែរ តាខៀវ សំផន?

យឿន ៖ ទេ! អ៊ំខៀវ សំផនដូចមិនឃើញស្គាល់ ។

ឈុនលី ៖ អត់ដែលស្គាល់?

យឿន ៖ អឺ! តែយើងវាមិនស្គាល់ មិនសូវហ៊ានសួរគេអ្នកធំៗ យើងខបមាថាដូចជាគេបើកវគ្គបើកអីភ្ញៀវៗបរទេស មានហើយមានអ្នកធំៗគេមក តែយើងម៉េចហ៊ានសួរគេ ទាល់តែអ្នកទុកចិត្តខ្ញុំបានខ្ញុំសួរ ។

ឈុនលី ៖ ហើយដល់ពេលពូនិយាយប្រាប់អ្នក ដែលថានិយាយដេរប៉ុលពតអីចឹង ហើយគាត់ថាម៉េចទៅ?

យឿន ៖ ទេ! ហើយគាត់ក៏ថាអឺ! អត់ស្គាល់ទេកូនអើយ ។ ចុះអ៊ឹងឯងអត់ស្គាល់ ម៉េចក៏ស្អប់គាត់? ចុះបើពុគេដេរចេះដេរនឹងគេទៅ តែហូបបាយហូបទឹកអីហៅទៅហើយ ហៅពួកខ្ញុំទៅផ្ទះគាត់នឹង ។

ឈុនលី ៖ កាលនឹងម៉េចពូទៅនឹង?

យឿន ៖ ចុះដល់វេណគេហៅទៅធ្វើការ ហៅទៅចូលភូមិចូលអីទៅ ។

ឈុនលី ៖ ហើយចឹងពូប្រាប់គេថាពូខ្មែរក្រហម?

យឿន ៖ អឺ! គេដឹងហើយ តែចូលទៅស្លៀកពាក់ខោអាវនឹងគេដឹងបាត់ហើយ ខោអាវចិន ។

ឈុនលី ៖ ខោអាវខ្មែរក្រហម ហើយនឹងខាងទាហានខាងក្នុងខុសគ្នាម៉េច?

យឿន ៖ អឺ! ខោអាវខាងក្នុងគេស្លៀកពាក់របៀបថាគេហៅពណ៌អីពណ៌អាចម៍ ។

ឈុនលី ៖ គគីរ?

យឿន ៖ គគីរអានឹង ។

ឈុនលី ៖ ពណ៌អាចម៍សេះ?

យឿន ៖ ហ៎! នេះៗ ។

ឈុនលី ៖ អាក្រៅនឹង?

យឿន ៖ បាទ!

ឈុនលី ៖ អានឹងទាហានខាងក្នុង?

យឿន ៖ បាទ!

ឈុនលី ៖ ចុះដល់ពេលខាងពូនេះវិញ?

យឿន ៖ ខាងនេះខោអាវចិន ។

ឈុនលី ៖ ពណ៌អីគេ?

យឿន ៖ ហ៎! ខោអាវគេនេះស្អាតណាស់ ស្លីកឈើ ។

ឈុនលី ៖ ពណ៌ខ្មៅដាក់ខាងនឹង?

យឿន ៖ ហ្នឹងហើយបើថាបន្ទា ជិះឡានអីបន្ទាគោណាស់ បើថាថ្មីអត់រហែកទេ ។

ឈុនលី ៖ ខោអាវចិន?

យឿន ៖ ហ្នឹងខោអាវចិន ។

ឈុនលី ៖ ចុះពូខទាហរណ៍ថាបើសិនជាមកដល់ឥឡូវនឹង ហើយពូធ្លាប់ដូចថាពួគេនិយាយថាខ្មែរក្រហម អាក្រក់អីចឹង និយាយពីរឿងអាក្រក់អីចឹង ហើយពូធ្វើម៉េចទៅ?

យឿន ៖ ទេ! អានឹងនិយាយអីនិយាយទៅ ធម្មតាយើងមិនទៅធ្វើអីឲ្យប៉ះពាល់ដល់ ។

ឈុនលី ៖ តែពូនឹងប្រាប់គេអត់ថាពូនឹងហើយជាខ្មែរក្រហម?

យឿន ៖ អឺ! តែនិយាយ តែគ្នាឯងនៅជិតនេះថានឹងហើយខ្មែរក្រហម តែគេនិយាយនេះហើយខ្មែរក្រហមៗ អីខ្មែរនឹង ខ្មែរដូចគ្នានឹង គេនិយាយអីនិយាយទៅ មានប៉ះពាល់អី ។

ឈុនលី ៖ ចុះបើតាមការគិតរបស់ពូៗគិតថាប្រជាជនភាគច្រើនគាត់ខឹងជាមួយខ្មែរក្រហមទេ?

យឿន ៖ ទេ! ប្រជាជនភាគច្រើននៅខាងនោះខឹងមែននឹងឯង គេសុទ្ធផ្នែកនយោបាយ ខាងនេះគេនៅខាងនេះគេបំពាក់បំប៉នខាងផ្នែកនយោបាយខាងនេះ នៅខាងនោះបំពាក់បំប៉នខាងផ្នែកនយោបាយខាងនោះ ។ ដល់ហើយនោះបន្ទាប់ខាងនេះ ទាល់នេះបន្ទាប់ខាងនេះ តែបូកសរុបទៅមិនដឹងជាអ្នកណាខុសអ្នកណាត្រូវ ខ្មែរដូចគ្នា ។ តែមែនទែនវាថារបៀបខ្ញុំគិតថាសង្គ្រាមដូចចាញ់បោកនយោបាយ ខ្មែរសម្លាប់ខ្មែរ អាបងសម្លាប់ប្អូនៗសម្លាប់... ខ្ញុំគំនិតខ្ញុំ តែយើងដូចអត់មានថាបញ្ចេញវាចាមកខាងក្រៅទេ នឹកក្នុងចិត្តរៀងខ្លួនទេ តែបើថាអ្នកទុកចិត្តអ្នកជិតស្និទ្ធនឹងគ្រាន់បញ្ចេញ ។

ឈុនលី ៖ ចុះអ្នកដទៃក៏គិតដូចពូដែរ?

យឿន ៖ អឺ! គិតដូចគ្នា ថាដុតធូបត្រូវគ្នា ថានៅព្រៃក៏ចឹងដែរ តែនេះធូរដុតធូបបុណ្យឲ្យត្រូវរូវគ្នាឲ្យសុខសាន្តនឹងគ្នា ។ ចុះបើវានឹកឃើញថា ហ៎!វៃខាងចាប់ប៉ុន្មានរយ៣០០នាក់ ។

ឈុនលី ៖ ចាប់បានខាងណា?

យឿន ៖ ខាងទាហានក្នុង និយាយពីដើរអត់រូបក្បាលជផ្គន់ឡើងត្រមែងៗ ។

ឈុនលី ៖ អត់អីហូប?

យឿន ៖ ហ្អឹងហើយ ។

ឈុនលី ៖ ចាញ់ទៀត?

យឿន ៖ ចាញ់ ហើយជ្រុះសក់ ។ យកមក១មានអីមេ ខ្ញុំគ្រាន់ចង់ទៅមើលខ្លាចមានអ្នកស្គាល់ គេដាក់គុក ។ មិនបាច់តែខ្មែរទេ សូម្បីតែយួនបាញ់ត្រូវនេះដាច់ជើងសែងយកមក១ព្យាបាលនៅពេទ្យយើង ព្យាបាលជាហើយលោកសុខ ភាពវិញ ថាឲ្យទៅស្រុកទេសវិញគេអត់ទៅ ។

ឈុនលី ៖ ចូលជាមួយយើងដែរ?

យឿន ៖ ហ្អឹង សុខចិត្តស្លាប់ជាមួយកម្ពុជា ចុះបើជាហើយ បាយក៏បាយស្រាប់ ចេះធ្វើចង្កេរ ធ្វើកញ្ច្រែងអីលក់លុយដាក់ហោប៉ៅខ្លួនឯង ហើយបាយហូបស្រាប់ មានយោបល់អី ។

ឈុនលី ៖ អានឹងពេលណាហើយ?

យឿន ៖ បាទ!ពេល ។

ឈុនលី ៖ នៅសម័យសង្គ្រាមនៅឡើយ?

យឿន ៖ ហ្អឹងហើយ សម័យសង្គ្រាម តែមិនដឹងឆ្នាំណាទេ រឿងសួរឆ្នាំអត់ចាំទេ ។

ឈុនលី ៖ ចុះបើគិតទៅ បើគេឲ្យពូទៅនៅខាងក្នុងពូនៅកើតអត់ ទៅស្រុកកំណើតវិញ ពេលសមាហរណកម្មហើយ ម៉េចបានអត់ទៅវិញ?

យឿន ៖ ចុះយើងអត់ដឹង អត់ដឹងថាបងប្អូនស្លាប់រស់ ម្យ៉ាងវានៅបែកនេះយូរហើយស្គាល់គ្នានេះច្រើនហើយ សុទ្ធតែមនុស្សរាប់គ្នានៅនឹងគេឯងទៅ ។ ហើយម្យ៉ាងទៅនោះវាអត់មានដីធ្លីមានដីឪពុកក៏គេភូមិគេដកអស់ មិនដូចខាងសៀមរាបគេដីទុកឲ្យ ។

ឈុនលី ៖ បើគិតទៅពូស្រឡាញ់ទឹកដីម៉ាខ្មែ?

យឿន ៖ និយាយថាស្រឡាញ់ក៏ថាបាន បើស្គាល់គ្នា រាប់គ្នានេះ ហើយម្យ៉ាងដីនេះក៏ចាប់បាននៅសមគួរ ហើយនោះដីស្រែប៉ុន្មានរៃ ភូមិគេដកហូតអស់ សូម្បីតែឪពុកនៅនោះហើយក៏គេនៅនោះមិនឲ្យផង ។

ឈុនលី ៖ ហើយនៅនេះយើងស្គាល់គ្នា យើងធ្លាប់នៅជាមួយគ្នាច្រើន?

យឿន ៖ បាទ!

ឈុនលី ៖ បើតាមពូគិតថា នៅក្នុងកំឡុងពេលដែលយើងមានរបបមានអី អ្នកគ្រប់គ្រងគេបើកឲ្យហើយបើប្រៀបធៀបមកឥឡូវយើងធ្វើការខ្លួនឯង រកស៊ីខ្លួនឯង ពូគិតថាមួយណាស្រួលវាស្រួលជាង?

យឿន ៖ ធ្វើម៉េចស្រួលដូចយើងរកស៊ីខ្លួនឯង ។

ឈុនលី ៖ អាហូបស្រាប់នៅអត់ស្រួលនឹង?

យឿន ៖ អាហូបស្រាប់វាស្រួល ក៏ប៉ុន្តែស្រេចគេប្រើគេបញ្ជាទៅនេះទៅនោះ ហើយជួនកាលបានទៅជួនកាលអត់ទៅ ស្រេចតែគេថាឥឡូវឡានគេមិនទាន់ដឹកមកបេះចុះ ។

ឈុនលី ៖ ហើយដល់ពេលនៅរកស៊ីខ្លួនឯង ទោះបីពេលខ្លះរកអត់បានអីចឹង វារៀងសប្បាយចិត្តដែរ?

យឿន ៖ ទេ! អានឹង បាទ!តាមដំណើរទៅ ។

ឈុនលី ៖ កូនដែរ?

យឿន ៖ កូន នេះហើយ បាត់ដង្ហើមប្រកាច់ដកឃ្លាទៅសៀមរាប ។

ឈុនលី ៖ ម៉េចចឹង?

យឿន ៖ វាឈឺ ម៉ែវាក៏ឈឺ អានេះក៏ឈឺ អាបងក៏ឈឺ ម៉ាផ្ទះខ្ញុំ ហើយយកទៅពេទ្យនោះ ហើយម៉ាយប់ដល់ថ្នាក់លោកគ្រូពេទ្យអាណិតខ្ញុំហើយ ។ ថាម៉ាយប់ៗគ្មានបានដេកប្រឈមភ្នែកប្រដាច់អណ្ដូតលានឡើង ។

ឈុនលី ៖ ប៉ុន្មានឆ្នាំហើយ?

យឿន ៖ នេះ១១ឆ្នាំ ។

ឈុនលី ៖ ឈឺតាំងពីតូច?

យឿន ៖ បាទ! អានេះអត់ទេ ឈឺកាលប៉ុន្មានខែមុន ឥឡូវទៅបើថ្នាំរាល់ខែ បើកសៀមរាប ។

ឈុនលី ៖ គេថាឈឺអី?

យឿន ៖ ទេ! គេអត់ប្រាប់ ពេទ្យខ្ញុំសួរម្ដងគេស្ដីឲ្យបេះដឹងអី ។

ឈុនលី ៖ ម៉េចចឹងពេទ្យនឹង?

យឿន ៖ គេអ្នកព្យាបាលគេដឹងហើយ តែឥឡូវនឹងគេហូប គេចាក់ថ្នាំ វាប្រកាច់យកទៅសៀមរាបគេបូមខួរចាក់ដល់នេះគេបូម ។ ដល់បូមទៅគេវៃថ្នាំទៅ តែឥឡូវ២ខែគេឲ្យទៅបើកថ្នាំម្ដងអានេះចូលលក្ខណៈរបេង ។

ឈុនលី ៖ របេងឆ្អឹង?

យឿន ៖ បាទ! តែសួរពេទ្យទៅ ពេទ្យនោះសួរៗពេលកំពុងព្យាបាលនឹង គេស្ដីឲ្យយើង ដល់ពេលចេញមកសួរគេប្រាប់ៗវាមិនទាន់ចូលទេ តែយើងលេបថ្នាំការពារ ព្រោះអីវាប្រកាច់ ។ ថាអ្នកអត់ដែលស្គាល់គ្នា ដេក...យំមុន ហើយម៉ែដើរអត់រួច នៅពេទ្យក្មួកកូនចឹង តែខំចែវក្មួកកូនចឹងមកជិតដល់ទន់ជើងដើរលែងរួច មានអ្នកទៅក្រោយកមកមើលកូន ។ ហើយកូននោះក្ដៅញាក់ក្ដៅទៅពេទ្យថតជងអូសអេកូជង... ។

ឈុនលី ៖ ថាចុះពូឥឡូវនេះមានធ្វើចំការធ្វើអីនឹងគេ?

យឿន ៖ អត់ៗមានចំការ ។

ឈុនលី ៖ ចុះអាត្រាក់នឹងធ្វើអីគេ?

យឿន ៖ អានឹងគោៗយន្តគេសម្រាប់ភ្ជួរដីធ្វើស្រែ ។

ឈុនលី ៖ ធ្វើស្រែ ប្រើគោយន្តស្រួលដែរ?

យឿន ៖ គោយន្តនឹងគោយន្តនឹងគេទិញឲ្យទៀតនឹង ។

ឈុនលី ៖ ខាងណាទិញ?

យឿន ៖ បងប្អូនរាប់អាននៅផ្សារនេះ គេឃើញខ្ញុំឃើញ...ទិញឲ្យ...តែធ្វើម៉េចកុំឲ្យបាត់ដើមទេ ឥឡូវមិនទាន់ឲ្យគេផង ។

ឈុនលី ៖ ប៉ុន្មានទៅពូ?

យឿន ៖ ហ៊ានចូលថៃទៅមានអី ការងារមិនខុះ តែយើងវាអត់វាខានយូរ ។

ឈុនលី ៖ កូនពូមានអ្នកណាទៅធ្វើការនៅថៃ?

យឿន ៖ អត់ទៅ មួយគេចង់អូសទៅដែរ ប៉ុនវាអត់ហ៊ាន...ថាអត់ចេះភាសាថៃ ។

ឈុនលី ៖ ភាគច្រើនគេធ្វើចំការធ្វើអីចឹង?

យឿន ៖ ហ្នឹងហើយ ។

ឈុនលី ៖ ធ្វើចំការ ធ្វើស្រែ?

យឿន ៖ ខ្វះគេអត់មាននើយហត់កាប់អីទេ... គេមានទឹកលុយ...ហើយខ្សោយកំរិតវប្បធម៌ផងខ្សោយគំនិតផង ។

ឈុនលី ៖ ចង់សួរមួយទៀត បើសិនជាឧទាហរណ៍ថា បើសិនជាយើងចង់ផ្សះផ្សាគ្នារវាងខ្មែរ ហើយជាមួយខ្មែរក្រហមអីចឹង ពូគិតថាអ្នកទាំងពីរនឹងគាត់រស់នៅឆ្ងាយគ្នា ហើយនឹងរស់នៅជិតគ្នាមួយណាអាចវាផ្សះផ្សាគ្នាត្រូវរ៉ូវគ្នាលឿនជាង?

យឿន ៖ អឺ! ..បើវាមិនដែលដឹង ។

ឈុនលី ៖ អត់ដឹងដែរ?

យឿន ៖ បាទ!

ឈុនលី ៖ ចុះពូមានអីសួរខ្ញុំវិញទេ?

យឿន ៖ មិនដឹងមានអីសួរផង ។

ឈុនលី ៖ អរគុណច្រើន ។

«ចប់»